Kingdom of Cambodia

Nation Religion King

Ministry of Economy and Finance

General Department of Taxation

# AMCHAM "Tax Update" Event

## H.E KONG VIBOL

Minister attached to prime minister and Delegate of the Royal Government in charge as the Director General , General Department of Taxation

AMCHAM CAMBODIA

# Meeting with AMCHAM (28/09/22)



GENERAL DEPARTMENT OF TAXATION

# Meeting with AMCHAM (28/09/22)



# A Brief Overview of Cambodia's Current Tax Landscape



## National Rectangular Strategy :

- The Rectangular Strategy Phase 4 (RS4) is the main strategy of the Government (current term)
- RS 4 focuses on acceleration of the Governance Reform **(Good Governance) as the core**
- RS 4 aims to promote Growth, Employment, Equity, and Efficiency
- RS 4 priorities: Roads, Water, Electricity, and People **(Human Resource as the top priority)**



# Rectangular Strategy Phase 4 (RS4)

- The Rectangular Strategy Phase 4 **(RS4) is the main strategy** of the Royal Government of Cambodia (RGC) under the current parliamentary term
- Previous Rectangular Strategy **(RS3) has set out Good Governance as the core strategy**, and **RS 4** has continued to focus on this and set **"Acceleration of the Governance Reform (Good Governance)" as the core of the strategy**
- The **main goals of the RS 4** are to promote **Growth**, **Employment**, **Equity**, and **Efficiency**.
- In achieving these goals, **RS 4 has set out 4 priorities** including **1)** Roads, **2)** Water, **3)** Electricity, and **4)** People, **with People (Human Resource) as the top priority** among the four.

# A Brief Overview of Cambodia's Current Tax Landscape

- **Transformation from traditional paper-based to IT-based systems (2012-2022).**
  - ✓ National Rectangular Strategy,
  - ✓ Public Financial Management Reform Program - PFMRP,
  - ✓ Revenue Mobilization Strategy – RMS.
  - ✓ Strategic Plan and Operational Plan
- GDT is now becoming a competently modern Tax Administration with the capacity and ability to effectively and consistently **achieve increased tax revenue collection year on year since 2012 to-date.**



# Revenue Mobilization Strategy 2019-2023 (RMS 2):

- RMS 2 is the **main strategy** outlining revenue collection roadmap for 2019 to 2023
- In formulating this strategy, **the RGC has adhered to 3 Strategic Approaches**, including:
  1. Ensuring the **sustainability of economic growth**,
  2. Ensuring the **sustainability of revenue growth** (at optimal level),
  3. Ensuring **fairness and level-playing field** in the enforcement of the tax and non-tax policies and collection, and
  4. Ensuring the **social justice** to relieve tax burdens on low-income people, improve people's welfare, and protect the environment.
- RMS 2 builds upon the success of previous RMS 2015-2018, and will **focus on modernizing** the **core operational functions**, and **supporting functions**, with **4 main expected outcomes**, including:
  1. Improvement of the **operational efficiency**
  2. Improvement of **voluntary compliance**
  3. Improvement of **service quality**
  4. Improvement of **outcome monitoring and evaluation mechanism** (key performance-based monitoring)
- As per this morning topic, I will elaborate one main expected outcome of the RMS 2, which is **"improvement of voluntary compliance"**, in which I will present about the 2 main aspects of Tax Compliance: **1). Voluntary Compliance**, and **2). Forced Compliance**.

# GDT-Tax Revenue Collection

## Act. Collection Vs. Target from 2011 to Present




| Description | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 (5Months) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Target By Law | $655.65 | $727.02 | $855.21 | $981.52 | $1,150.49 | $1,404.01 | $1,694.64 | $1,899.63 | $2,260.16 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 |
| Actual | $582.73 | $731.39 | $870.49 | $1049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,170.78 | $2,784.52 | $2,889.02 | $2,781.92 | $3,455.11 | $1,826.69 |
| %Actual | 88.88% | 103.12% | 104.08% | 107.40% | 111.82% | 105.70% | 115.20% | 114.27% | 123.20% | 102.46% | 124.02% | 122.54% | 51.14% |

Update : 31/05/23

# GDT-Tax Revenue Collection

## Act. Collection Vs. Target from 2011 to Present

**MEF has projected the tax revenue target for 2024 to approximately $ 4,162 Million.**




| Description | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 (5Months) | 2024 (Est.) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Target By Law | $655.65 | $727.02 | $855.21 | $981.52 | $1,150.49 | $1,404.01 | $1,694.64 | $1,899.63 | $2,260.16 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 | $4,162 |
| Actual | $582.73 | $731.39 | $870.49 | $1049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,170.78 | $2,784.52 | $2,889.02 | $2,781.92 | $3,455.11 | $1826.69 | |
| %Actual | 88.88% | 103.12% | 104.08% | 107.40% | 111.82% | 105.70% | 115.20% | 114.27% | 123.20% | 102.46% | 124.02% | 122.54% | 51.14% | |

Update : 31/05/23

# Cambodia's GDP growth

## Graphic : GDP Growth




Source : National Institute of Statistics and Ministry of Economy and Finance

For 2023, Cambodia's GDP growth was expected to be at 5.6%, GDT Tax revenue collection was expected to achieve 105% in 2023, and for next year (2024), the tax revenue target is set to be at approximately $4,162 Billion, despite not introducing any new tax, and introducing many tax incentives. As such, GDT will continue to enhance good governance, good administration, enforcing the tax base, and formalize the informal sectors through our tax registration mechanism.

# Way forwards measures

- Prepare tracking mechanism to ensure transparency such as, **RFID and GPS technology**
- Enhancing registration and VAT collection on **E-Commerce**
- Feasibility study on **QR Code Printing technology** on Can and Bottle of the Beer and beverages products,
- Study on implementation of new technologies and their implication on taxation such as **Blockchain technology**, and
- Enforcing and Enhancing Tax collections for sectors with revenue potential, such as **Telecommunication industry, Mining industry, and Logistics, etc.**

# Recent tax policies and modernization updates

## i. Tax Policy:

- **New Law on Taxation,** which is the main topic of today's event.

- **Draft Sub-Decree on Law on Investment:** Where many tax incentive were given as per the Law on Investment for some specific sectors, such as high-tech industries, some manufacturing industries, agriculture, education, health and digital industries. The tax incentive consists of:

  i. **basic incentive scheme** which provides exemption for Tax on Income (ToI) up to 9 years, special depreciation, and deduction up to 200% for some specific expenses and

  ii. **additional incentive scheme** which includes VAT exemption, special deduction up to 150% for some expenses, and entitlement to tax on income exemption for the expansion of QIP.

- **Anti-Money Laundering (AML):** GDT has been actively participated in the AML Committee and Working Group. As a result, Cambodia has been taken out of the Grey List by FATF on 24th February 2023. Further, GDT has been awarded for our effort to combat AML, especially through tax crime investigation.

- **Cambodia-Macau DTA**, which will come into effective in 01st January 2024.

# Recent tax policies and modernization updates

i. **Tax Administrations:**

- **E-Filing and E-Payment** adoption, where our services continue to get better and currently over 90% of the taxpayers has used our E-Filing and E-Payment systems as opposed to manual tax return filing.

- **E-Administration System,** where we are currently develop comprehensive management system to promote productivity.

- **Invoice Lucky Draw and VAT Cross-Check System:** where Tax Administration is able to hit many birds with one stone suing the information we have collected.

- **Online Tax on Income Tax Return Adjustment:** allowing taxpayers to submit request to make adjustment on their Tax on Income tax returns.

- **Strengthening Tax Stamp on Cigarette Product:** where we have visited the markets

# THANK YOU




# ច្បាប់

## ស្តីពី

# សារពើពន្ធ

## ប្រកាសឱ្យប្រើដោយ
## ព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

# មាតិកា

១ គោលបំណងនៃការរៀបចំ

២ ច្បាប់ស្តីពីសារពើពន្ធ

# ១- គោលបំណងនៃការរៀបចំ

## ដើម្បីធានាបាននូវ ៖

ចីរភាពនៃការកៀរគរចំណូល ការជំរុញកំណើនសេដ្ឋកិច្ចជាតិ ការប្រកួតប្រជែងដោយស្មើភាព និងយុត្តិធម៌ សមធម៌សង្គម និងការបន្តលើកកម្ពស់គុណភាពសេវាជូនអ្នកជាប់ពន្ធឱ្យបានកាន់តែល្អ រហ័ស សាមញ្ញ និងងាយស្រួល ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល។

# ១- គោលបំណងនៃការរៀបចំ ( ត )

ប្រមូលផ្តុំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន នៅក្រោមក្រឹត្យ-ច្បាប់នានា និងច្បាប់ស្តីពីសារពើពន្ធបច្ចុប្បន្ន ព្រមទាំងវិសោធនកម្មជាបន្តបន្ទាប់ ក្នុងគោលបំណងផ្តល់ភាពងាយស្រួលក្នុងការស្វែងរក និងអនុវត្ត។

កែសម្រួល និងបំពេញបន្ថែមនូវបទប្បញ្ញត្តិដែលមានភាពខ្វះចន្លោះ ដោយផ្អែកលើមូលដ្ឋានមួយចំនួនជាអាទិ៍៖ បទពិសោធន៍និងការលើកឡើងនានារបស់វិស័យឯកជនក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងឧត្តមានុវត្តន៍អន្តរជាតិ។

ដាក់បញ្ចូលនូវគោលការណ៍ទន់ភ្លន់ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់ការលើកទឹកចិត្តផ្នែកពន្ធដារមួយចំនួនក្នុងករណីដែលកម្ពុជាប្រឈមនឹងវិបត្តិសេដ្ឋកិច្ច ឬវិបត្តិហិរញ្ញវត្ថុ ឬគ្រោះអាសន្ន ឬតម្រូវការចាំបាច់បន្ទាន់នានាក្នុងការធានាលំនឹងជីវភាព និងសុខុមាលភាពរបស់ប្រជាជនក៏ដូចជាក្នុងការធានានូវប្រក្រតីភាពនៃកិច្ចដំណើរការសង្គម-សេដ្ឋកិច្ច។

បើកផ្លូវឱ្យមានការចូលរួមអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ស្របតាមការវិវត្តនៃសង្គមសេដ្ឋកិច្ចនិងបរិបទថ្មីនៃវិស័យធុរកិច្ច តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទំនើបក្នុងការកៀរគរ និងគ្រប់គ្រងការប្រមូលចំណូល។

គិតគូរជានាការរៀបចំច្បាប់ឱ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តក៏ដូចជាការរៀបចំឱ្យមានសង្គតិភាពទាំងខាងទម្រង់និងទាំងខាងខ្លឹមសារជាមួយច្បាប់ពាក់ព័ន្ធនានា។

# ២- ច្បាប់ស្តីពីសារពើពន្ធ

## រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ៖

| បទប្បញ្ញត្តិស្តីពីពន្ធដារ | | | | ច្បាប់ស្តីពីសារពើពន្ធ (ដែលដាក់ឱ្យប្រើប្រាស់ ដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០២៣ |
|---|---|---|---|---|
| មាត្រា, ជំពូក, ប្រភេទពន្ធអាករ | ក្រឹត្យ-ច្បាប់ចាប់ពីឆ្នាំ១៩៨២ | ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ | ច្បាប់ស្តីពីសារពើពន្ធ (ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់) | |
| ចំនួនមាត្រានិងជំពូក | | | ១៥៥មាត្រា/៧ជំពូក | ២៥៥មាត្រា/២០ជំពូក |
| ប្រភេទពន្ធនិងអាករ | **៤ ប្រភេទពន្ធ**<br>១).ពន្ធប៉ាតង់<br>២).ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ<br>៣).ពន្ធប្រថាប់ត្រា<br>៤).ពន្ធតែមប្រើសារពើពន្ធ | **៦ ប្រភេទពន្ធ**<br>១).ពន្ធលើឈ្នួលផ្ទះនិងដី<br>២).ពន្ធលើដីធ្លីមិនបានប្រើប្រាស់<br>៣). អាករសម្រាប់បំភ្លឺសាធារណៈ<br>៤).អាករលើការស្នាក់នៅ<br>៥).ពន្ធលើចំណេញមូលធនដែលសម្រេចបានដោយរូបវន្តបុគ្គល<br>៦). ពន្ធលើអចលនទ្រព្យ | **៥ ប្រភេទ**<br>១).ពន្ធលើប្រាក់ចំណូល<br>២).ពន្ធលើប្រាក់បៀវត្ស<br>៣).អាករលើតម្លៃបន្ថែម<br>៤).អាករពិសេសលើទំនិញនិងសេវាមួយចំនួន<br>៥).ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ | **១៥ ប្រភេទពន្ធ** |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

**សម្គាល់៖**

ប្រភេទពន្ធមួយចំនួនត្រូវបានប្តូរឈ្មោះក្នុងច្បាប់ស្តីពីសារពើពន្ធ ២០២៣៖

១- អាករពិសេសលើទំនិញនិងសេវាមួយចំនួន ត្រូវបានប្តូរជា "**អាករពិសេស**"។

២- ពន្ធលើឈ្នួលផ្ទះ និងដី ត្រូវបានប្តូរជា "**ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ**"។

៣- ពន្ធតែមប្រិ៍សារពើពន្ធ ត្រូវបានប្តូរជា "**ពន្ធលើផ្ទាំងផ្សព្វផ្សាយ**"។

៤- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបានប្តូរជា "**ពន្ធលើមធ្យោបាយដឹកជញ្ជូន**"។

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## រចនាសម្ព័ន្ធនៃច្បាប់ស្ដីពីសារពើពន្ធ (ត)

| ជំពូក | | ចំនួនផ្នែក | ចំនួនមាត្រា | លំដាប់រៀងមាត្រា |
|---|---|---|---|---|
| ជំពូកទី ១ | បទប្បញ្ញត្តិទូទៅ | - | ២ | ១ ដល់ ២ |
| ជំពូកទី ២ | ពន្ធលើប្រាក់ចំណូល | ៩ | ៣៧ | ៣ ដល់ ៣៩ |
| ជំពូកទី ៣ | ពន្ធលើប្រាក់បៀវត្ស | ៤ | ១៥ | ៤០ ដល់ ៥៤ |
| ជំពូកទី ៤ | អាករលើតម្លៃបន្ថែម | ៥ | ៣០ | ៥៥ ដល់ ៨៤ |
| ជំពូកទី ៥ | អាករពិសេស | - | ៧ | ៨៥ ដល់ ៩១ |
| ជំពូកទី ៦ | អាករសម្រាប់បំភ្លឺសាធារណៈ | - | ៨ | ៩២ ដល់ ៩៩ |
| ជំពូកទី ៧ | អាករលើការស្នាក់នៅ | - | ៨ | ១០០ ដល់ ១០៧ |
| ជំពូកទី ៨ | ពន្ធប៉ាតង់ | - | ៨ | ១០៨ ដល់ ១១៥ |
| ជំពូកទី ៩ | ពន្ធលើផ្ទាំងផ្សព្វផ្សាយ | - | ៨ | ១១៦ ដល់ ១២៣ |
| ជំពូកទី ១០ | ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ | ៥ | ១៥ | ១២៤ ដល់ ១៣៨ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ (ត)

| ជំពូក | | ចំនួនផ្នែក | ចំនួនមាត្រា | លំដាប់រៀងមាត្រា |
|---|---|---|---|---|
| ជំពូកទី ១១ | ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ | - | ៨ | ១៣៩ ដល់ ១៤៦ |
| ជំពូកទី ១២ | ពន្ធលើអចលនទ្រព្យ | - | ៨ | ១៤៧ ដល់ ១៥៤ |
| ជំពូកទី ១៣ | ពន្ធប្រថាប់ត្រា | - | ១០ | ១៥៥ ដល់ ១៦៤ |
| ជំពូកទី ១៤ | ពន្ធលើចំណេញមូលធន | - | ៨ | ១៦៥ ដល់ ១៧២ |
| ជំពូកទី ១៥ | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | - | ៨ | ១៧៣ ដល់ ១៨០ |
| ជំពូកទី ១៦ | ពន្ធលើមធ្យោបាយដឹកជញ្ជូន | - | ៨ | ១៨១ ដល់ ១៨៨ |
| ជំពូកទី ១៧ | វិធាននិងនីតិវិធីសារពើពន្ធ | ៧ | ៣២ | ១៨៩ ដល់ ២២២ |
| ជំពូកទី ១៨ | ទោសប្បញ្ញត្តិ | ៥ | ៣១ | ២២៣ ដល់ ២៥២ |
| ជំពូកទី ១៩ | អន្តរប្បញ្ញត្តិ | - | ១ | ២៥៣ |
| ជំពូកទី ២០ | អវសានប្បញ្ញត្តិ | - | ២ | ២៥៤ ដល់ ២៥៥ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ (ត)

**មាត្រាសរុបនៃច្បាប់ស្តីពីសារពើពន្ធមានចំនួន ២៥៥មាត្រា**

**២.១. មាត្រាដែលមិនត្រូវបានធ្វើវិសោធនកម្មមានចំនួន ៩មាត្រា**

**២.២. មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា**

| | |
|---|---|
| ក- ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលំដាប់៖ | ៧៤មាត្រា |
| ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ៖ | ៥៣មាត្រា |
| គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង៖ | ៦១មាត្រា |
| ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន៖ | ៥៨មាត្រា |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ២.១. មាត្រាដែលមិនត្រូវបានធ្វើវិសោធនកម្មមានចំនួន ៩មាត្រា

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី២ ស្តីពីពន្ធលើប្រាក់ចំណូល (១មាត្រា) | មាត្រា៣១ |
| ជំពូកទី៣ ស្តីពីពន្ធលើប្រាក់បៀវត្ស (១មាត្រា) | មាត្រា៤៩ |
| ជំពូកទី១០ ស្តីពីពន្ធពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ (៣មាត្រា) | មាត្រា១២៥, មាត្រា១២៩, មាត្រា១៣៧ |
| ជំពូកទី១៧ ស្តីពីវិធាននិងនីតិវិធីសារពើពន្ធ(៣មាត្រា) | មាត្រា១៩៩, មាត្រា២០៥, មាត្រា២១៤ |
| ជំពូកទី២០ ស្តីពីអវសានប្បញ្ញត្តិ (១មាត្រា) | មាត្រា២៥៥ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ២.២. មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា

ក- ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលំដាប់៖ ៧៤មាត្រា

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី២ ស្តីពីពន្ធលើប្រាក់ចំណូល (២២មាត្រា) | មាត្រា៤, មាត្រា៦, មាត្រា ៧, មាត្រា៨, មាត្រា១៦, មាត្រា១៧, មាត្រា១៩, មាត្រា២០, មាត្រា២១, មាត្រា២២, មាត្រា២៣, មាត្រា២៦, មាត្រា២៧, មាត្រា២៩, មាត្រា៣០, មាត្រា៣២, មាត្រា៣៤, មាត្រា៣៥, មាត្រា៣៦, មាត្រា៣៧, មាត្រា៣៨, មាត្រា៣៩ |
| ជំពូកទី៣ ស្តីពីពន្ធលើប្រាក់បៀវត្ស (៦មាត្រា) | មាត្រា៤៣, មាត្រា៤៧, មាត្រា៥០, មាត្រា៥១, មាត្រា៥២, មាត្រា៥៣ |
| ជំពូកទី៤ ស្តីពីអាករលើតម្លៃបន្ថែម (១៧មាត្រា) | មាត្រា៥៧, មាត្រា៦១, មាត្រា៦២, មាត្រា៦៥, មាត្រា៦៦, មាត្រា៦៧, មាត្រា៧០, មាត្រា៧១, មាត្រា៧២ មាត្រា៧៣, មាត្រា៧៤, មាត្រា៧៦, មាត្រា៧៧, មាត្រា៧៩, មាត្រា៨១, មាត្រា៨២,មាត្រា៨៣ |
| ជំពូកទី១០ ស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ (៩មាត្រា) | មាត្រា១២៦, មាត្រា១២៧, មាត្រា១២៨, មាត្រា១៣០, មាត្រា១៣១, មាត្រា១៣២, មាត្រា១៣៣, មាត្រា១៣៥, មាត្រា១៣៦ |
| ជំពូកទី១៧ ស្តីពីវិធាននិងនីតិវិធីសារពើពន្ធ (២០មាត្រា) | មាត្រា១៨៩, មាត្រា១៩២, មាត្រា១៩៣, មាត្រា១៩៧, មាត្រា២០០, មាត្រា២០១, មាត្រា២០៤, មាត្រា២០៧, មាត្រា២០៨,មាត្រា២០៩, មាត្រា២១១, មាត្រា២១២, មាត្រា២១៦,មាត្រា២២២, មាត្រា២២៣, មាត្រា២២៤, មាត្រា២៣៣, មាត្រា២៣៧, មាត្រា២៣៨, មាត្រា២៥៤ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

ក- ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលុបចោល
*ដកស្រង់យកតែ ៥មាត្រា

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល<br><br>មាត្រា២.. កម្មវត្ថុនៃពន្ធ<br>ពន្ធលើប្រាក់ចំណូល គឺជាបំណុលរបស់បុគ្គលនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស និងរបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។ | → | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br><br>មាត្រា៤..វិសាលភាពនៃពន្ធ<br>ពន្ធលើប្រាក់ចំណូល អនុវត្តលើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស និងអ្នកជាប់ពន្ធអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ក-ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលំដាប់(ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល<br><br>**មាត្រា១៦.- វិភាគទានសប្បុរសធម៌**<br>១- ត្រូវបានអនុញ្ញាតឱ្យផាត់ចេញនូវវិភាគទានសប្បុរសធម៌ ដែលបានបរិច្ចាគឱ្យអង្គការនានា ដូចមានចែងក្នុងមាត្រា ៩ថ្មី នៃច្បាប់នេះ ប៉ុន្តែមិនត្រូវឱ្យលើសពី៥ភាគរយនៃ ប្រាក់ចំណូលជាប់ពន្ធមុនពេលកាត់កងវិភាគទាន សប្បុរសធម៌ទាំងនោះឡើយ។<br>២- លក្ខណវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ ត្រូវ កំណត់ដោយអនុក្រឹត្យ។ | | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br><br>**មាត្រា១៦.- វិភាគទានសប្បុរសធម៌**<br>១- ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវវិភាគទានសប្បុរសធម៌ ដែលបានបរិច្ចាគឱ្យអង្គការនានា ដូចមានចែងក្នុង មាត្រា៩ នៃច្បាប់នេះ ប៉ុន្តែមិនត្រូវឱ្យលើសពី៥ (ប្រាំ) ភាគរយនៃប្រាក់ចំណូលជាប់ពន្ធមុនពេលកាត់កង វិភាគទានសប្បុរសធម៌ទាំងនោះឡើយ។<br>២- លក្ខណវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ ត្រូវ កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ក-ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលុបចោល(ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី២ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់បៀវត្ស</u><br><br>**មាត្រា៤៣.- ប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀត**<br>ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចតទៅ៖ | → | <u>ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស</u><br><br>**មាត្រា៤៣.- ប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀត**<br>ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចខាងក្រោម៖ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ក-ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលុំដាប់(ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម**<br>**មាត្រា៦៤._ អត្រាអាករ**<br>អត្រាអាករត្រូវបានកំណត់ដូចតទៅ៖<br>១- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>២- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា០ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦៣នៃច្បាប់នេះ។<br>៣- រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែង ក្នុងនោះមានជាអាទិ៍ សេចក្តីបញ្ជាក់ការនាំចេញរបស់ទីចាត់ការគយ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់ និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល។ | → | **ជំពូកទី៤ អាករលើតម្លៃបន្ថែម**<br>**មាត្រា៦៥._ អត្រាអាករ**<br>អត្រាអាករត្រូវបានកំណត់ដូចខាងក្រោម៖<br>១- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០(ដប់)ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>២- អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា០(សូន្យ)ភាគរយលើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ។<br>៣- រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែង ក្នុងនោះមានជាអាទិ៍ ប្រតិវេទន៍គយនាំចេញរបស់រដ្ឋបាលគយ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់ និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ក-ចំនួនមាត្រាដែលត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយតូច ពាក្យពេចន៍ ឬដាក់បញ្ចូលគ្នាឬលុបចោល(ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u> | | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u> |
| **មាត្រា៩០.-ភាសាប្រើនៅក្នុងលិខិតប្រកាសនិងឯកសារសារពើពន្ធ**<br>លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារ និងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់ពន្ធដារ ឬដែលជាប់ទាក់ទិននឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ។ | → | **មាត្រា១៩២.-ភាសាប្រើនៅក្នុងលិខិតប្រកាសនិងឯកសារសារពើពន្ធ**<br>លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារ និងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ឬដែលទាក់ទិននឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ។ |

## ២.២. មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា

### ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារៈ ៥៣មាត្រា

| ជំពូក | មាត្រា |
|---|---|
| ជំពូក២ ស្តីពីពន្ធលើប្រាក់ចំណូល (១១មាត្រា) | មាត្រា៥, មាត្រា១០, មាត្រា១១, មាត្រា ១៣, មាត្រា១៤, មាត្រា១៥, មាត្រា១៨, មាត្រា២៤, មាត្រា២៥, មាត្រា២៨, មាត្រា៣៣ |
| ជំពូក៣ ស្តីពីពន្ធលើប្រាក់បៀវត្ស (៥មាត្រា) | មាត្រា៤២, មាត្រា៤៤, មាត្រា៤៥, មាត្រា៤៦, មាត្រា៤៨ |
| ជំពូក៤ ស្តីពីអាករលើតម្លៃបន្ថែម (៩មាត្រា) | មាត្រា៥៨, មាត្រា៥៩, មាត្រា៦០, មាត្រា៦៣, មាត្រា៦៤, មាត្រា៦៨, មាត្រា៦៩, មាត្រា៧៨, មាត្រា៨០ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ២.២.មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា (ត)

### ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី១០ ស្ដីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ (១មាត្រា) | មាត្រា១៣៤ |
| ជំពូកទី១៧ ស្ដីពីវិធាននិងនីតិវិធីសារពើពន្ធ (១៥មាត្រា) | មាត្រា១៩០, មាត្រា១៩១, មាត្រា១៩៤, មាត្រា១៩៥, មាត្រា១៩៨, មាត្រា២០២, មាត្រា២០៣, មាត្រា២០៦, មាត្រា២១០, មាត្រា២១៣, មាត្រា២១៧, មាត្រា ២១៨, មាត្រា២១៩, មាត្រា២២០, មាត្រា២២១ |
| ជំពូកទី១៨ ស្ដីពីទោសប្បញ្ញត្តិ (១២មាត្រា) | មាត្រា២២៥, មាត្រា២២៦, មាត្រា២២៨, មាត្រា២៣០, មាត្រា២៣២, មាត្រា២៣៥, មាត្រា២៣៦, មាត្រា២៣៩, មាត្រា២៤០, មាត្រា២៤២, មាត្រា២៤៣, មាត្រា២៤៤ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

*ដកស្រង់យកទាំង ៥៣មាត្រា

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៣.. (ថ្មី) និយមន័យ**<br>៣- ពាក្យ "នីតិបុគ្គល" សំដៅដល់សហគ្រាសឬអង្គការនានាដែលប្រកបអាជីវកម្មទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្ដី។ ពាក្យ "នីតិបុគ្គល" រួមបញ្ចូលផងដែរនូវក្រុមហ៊ុនមូលធន ស្ថាប័នរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកចំណេញ ឬគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសជនដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពាក្យ "នីតិបុគ្គល" ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិ ឬសហគ្រាសឯកបុគ្គល។ | → | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៥.. និយមន័យ**<br>៣- នីតិបុគ្គល សំដៅដល់ សហគ្រាសឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្ដី។ ពាក្យនីតិបុគ្គល រួមបញ្ចូលផងដែរនូវស្ថាប័នរាជរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកចំណេញ សមាគម គណបក្សនយោបាយ និងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់តែគោលដៅនៃការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល ពាក្យ នីតិបុគ្គល ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិឬសហគ្រាសឯកបុគ្គល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល**<br>**មាត្រា៣.. (ថ្មី) និយមន័យ**<br>៤- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" រួមបញ្ចូលផងដែរនូវបណ្តាញ ឬបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះ បុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ | → | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br>**មាត្រា៥.. និយមន័យ**<br>៤- គ្រឹះស្ថានអចិន្ត្រៃយ៍ សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជនដែលនៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។ ពាក្យ គ្រឹះស្ថានអចិន្ត្រៃយ៍ រួមបញ្ចូលផងដែរនូវបណ្តាញឬបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះ បុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | បុគ្គលណាមួយអាចត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីបុគ្គលនោះមាននិងអនុវត្តជាប្រចាំនូវសិទ្ធិអំណាចក្នុងការចុះកិច្ចសន្យាក្នុងនាមបុគ្គលអនិវាសនជននោះ ឬបំពេញតួនាទីចម្បងក្នុងការសម្របសម្រួលដើម្បីឈានដល់ការចុះកិច្ចសន្យា។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជា ប៉ុណ្ណោះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល<br><br>**មាត្រា៣.. (ថ្មី) និយមន័យ**<br><br>៥- ពាក្យ"ក្រុមហ៊ុនសហកម្មសិទ្ធិ" សំដៅដល់សហគ្រាសដែលបង្កើតឡើងដោយរូបវន្តបុគ្គលពីរ ឬច្រើននាក់ ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ឬចំណេះដឹង ឬសកម្មភាពរបស់រូបវន្តបុគ្គលទាំងនោះដើម្បីប្រកបអាជីវកម្មរួមគ្នា។ ក្នុងនិយមន័យនេះ ក្រុមហ៊ុនសហកម្មសិទ្ធិរួមមាន ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនសហកម្មសិទ្ធិមិនអាចជាសមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិណាមួយ ហើយក៏មិនរាប់បញ្ចូលផងទេនូវក្រុមហ៊ុនមូលធន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯក-បុគ្គល។ | → | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br><br>**មាត្រា៥.. និយមន័យ**<br><br>៥- ក្រុមហ៊ុនសហកម្មសិទ្ធិ សំដៅដល់ សហគ្រាសដែលបង្កើតឡើងដោយកិច្ចសន្យារវាង បុគ្គលពីរឬច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិឬចំណេះដឹងឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបអាជីវកម្មឬពាណិជ្ជកម្មរួមក្នុងគោលបំណងរកប្រាក់ចំណេញ។ ក្នុងនិយមន័យនេះ ក្រុមហ៊ុនសហកម្មសិទ្ធិ រួមមាន ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | លក្ខខណ្ឌដើម្បីទទួលបាននូវនីតិបុគ្គល ឬនីតិបុគ្គលិកលក្ខណៈនៃក្រុមហ៊ុនសហកម្មសិទ្ធិដូចមានកំណត់ក្នុងច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មនិងច្បាប់ដទៃជាធរមាន មិនត្រូវបានយកមកអនុវត្តសម្រាប់គោលបំណងប្រមូលពន្ធលើប្រាក់ចំណូលឡើយ។ ក្រុមហ៊ុនសហកម្មសិទ្ធិ មិនរាប់បញ្ចូលទេនូវក្រុមហ៊ុនមូលធន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯកបុគ្គល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៣.. (ថ្មី) និយមន័យ**<br>១០- ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់ ៖<br>ក- សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ។<br>ខ- សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិ ចាប់ពី ៥១ភាគរយ ឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស ។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនរបស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។ | → | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៥.. និយមន័យ**<br>១០- ពាក្យ "បុគ្គលទាក់ទិន" សំដៅដល់៖<br>ក- សមាជិកណាម្នាក់ក្នុងវង្សញាតិ អ្នកជាប់ពន្ធ។<br>ខ- សហគ្រាសដែលគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល លើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ឬទំនាក់ទំនងរវាងគ្រឹះស្ថានអចិន្ត្រៃយ៍ និងអ្នកជាប់ពន្ធអនិវាសនជន។ ពាក្យ "គ្រប់គ្រង" មានន័យថាមានកម្មសិទ្ធិចាប់ពី ២០ (ម្ភៃ) ភាគរយ ឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ ឬ ប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។ ដោយមិនគិតពីលក្ខខណ្ឌខាងលើនេះ រដ្ឋបាលសារពើពន្ធអាចវិនិច្ឆ័យលើការគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោលទៅតាមករណីជាក់ស្តែងនីមួយៗ ដើម្បីកំណត់ថាមានឬគ្មានការគ្រប់គ្រង។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **មាត្រា៥.. និយមន័យ**<br>១២- ពាក្យ "សម្ព័ន្ធអាជីវកម្ម" សំដៅដល់ សកម្មភាពអាជីវកម្មរួមគ្នារវាងអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន ឬអ្នកជាប់ពន្ធ អនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន ចាប់ពីពីរឡើងទៅដោយមិនបង្កើតជានីតិបុគ្គលដាច់ដោយឡែកឡើយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល**<br>**មាត្រា១០._ ការកំណត់ប្រាក់ចំណូលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ**<br>ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ឆ្នាំជាប់ពន្ធណាមួយសមាជិកម្នាក់ៗ ត្រូវគិតជាចំដោយឡែកពីគ្នានូវចំណែករៀងៗខ្លួន នៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កង ឥណទាននិងវិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ។ សម្រាប់គោលដៅនេះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថាបានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមានឬគ្មានការបែងចែកជាក់ស្តែងក្តី ។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំមុខនឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់នានាហើយ។ | | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br>**មាត្រា១០_ ការកំណត់ប្រាក់ចំណូលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ និងសម្ព័ន្ធអាជីវកម្ម**<br>១- ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិនិងសម្ព័ន្ធអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ឆ្នាំជាប់ពន្ធណាមួយ សមាជិកម្នាក់ៗត្រូវគិតជាចំដោយឡែកពីគ្នានូវចំណែករៀងៗខ្លួននៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កង ឥណទាន និងវិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ។ សម្រាប់គោលដៅនេះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថាបានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមានឬគ្មានការបែងចែកជាក់ស្តែងក្តី។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំបន្ទាប់នឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់នានាហើយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| វិធានសម្រាប់កំណត់ចំនួនទឹកប្រាក់ដែលត្រូវបែងចែកការចាត់ចែងចំពោះវិភាគទានផ្សេងៗនិងការកែតម្រូវទៅលើចំណែកជាមូលដ្ឋានរបស់សមាជិកម្នាក់ៗនៃក្រុមហ៊ុន សហកម្មសិទ្ធិនៅក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវកំណត់ដោយអនុក្រឹត្យ។ | → | ២- វិធាននិងនីតិវិធី នៃការកំណត់ប្រាក់ចំណូលរបស់សមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិនិងសម្ព័ន្ធអាជីវកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល</u><br><br>មាត្រា១១.. ការកាត់កងដែលអនុញ្ញាត<br>ច្បាប់ចាស់ពុំមានចែងពីការកាត់ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានោះទេ។ | → | <u>ជំពូកទី២ ពន្ធលើប្រាក់ចំណូល</u><br><br>មាត្រា១១.. ការកាត់កងដែលអនុញ្ញាត<br>៦- ការកាត់កងចំណាយរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលទទួលបានតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល**<br>**មាត្រា១៣ .-ថ្មី វំលស់ទ្រព្យរូបី**<br><br>១- លក្ខខណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចតទៅ៖<br>ក- ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងសម្រាប់រំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យរូបីឬអ្នកជួលទ្រព្យរូបី ក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ឬការខូតខាតនៃទ្រព្យ ស្របតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ខ- ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ឬភាពហួសសម័យ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ<br>គ-ទ្រព្យរូបីទាំងអស់ ត្រូវបានបែងចែកជាថ្នាក់ដូចតទៅ៖ | → | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br>**មាត្រា១៣.. រំលស់ទ្រព្យរូបី**<br>១-លក្ខខណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចខាងក្រោម៖<br>ក- ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងសម្រាប់រំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យរូបីឬអ្នកជួលទ្រព្យរូបីក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ ឬការខូតខាតនៃទ្រព្យស្របតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ខ- ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ឬភាពហួសសម័យ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ<br>គ- ទ្រព្យរូបីទាំងអស់ត្រូវបានបែងចែកជាថ្នាក់និងវិធីរំលស់ដូចខាងក្រោម៖ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ថ្នាក់១ : អាគារនិងរចនាសម្ព័ន្ធ ព្រមទាំងសមាសភាគរបស់វា។ អត្រារំលស់ ៥ភាគរយ តាមវិធីរំលស់ស្មើភាគ<br><br>ថ្នាក់២ : កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិក សហ្វវែរនិងបរិក្ខារទុកដាក់ទិន្នន័យ។ អត្រារំលស់ ៥០ភាគរយ តាមវិធីរំលស់ថយដាលំដាប់<br>ថ្នាក់៣ : រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹមនិងបរិក្ខារការិយាល័យ។ អត្រារំលស់ ២៥ភាគរយ តាមវិធីរំលស់ថយដាលំដាប់<br>ថ្នាក់៤ : ទ្រព្យរូបីឯទៀតទាំងអស់ អត្រារំលស់ ២០ភាគរយ តាមវិធីរំលស់ថយដាលំដាប់<br>[...] | → | ថ្នាក់១៖សំណង់នានារួមបញ្ចូលទាំង អគារនិងរចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគរបស់អគារ ផ្លូវថ្នល់ ផ្លូវដែក នាវាដឹកជញ្ជូន ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគ<br><br>ថ្នាក់២៖កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិក ឧបករណ៍អេឡិចត្រូនិកនិងបរិក្ខារផ្ទុកទិន្នន័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយដាលំដាប់<br><br>ថ្នាក់៣៖រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារិម និងបរិក្ខារការិយាល័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយដាលំដាប់<br><br>ថ្នាក់៤៖ ទ្រព្យសកម្មរូបីដ៏ទៃទៀត ត្រូវធ្វើរំលស់តាមវិធីរំលស់ថយដាលំដាប់។<br><br>[...] |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
| --- | --- | --- |
| គ- ទ្រព្យរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេសត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤ ឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ អ្នកវិនិយោគត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កង កាត់បន្ថយដោយចំនួនមួយស្មើនឹង ២ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់។ ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបីសម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធតាមមាត្រា៧ថ្មី (មួយ) នៃច្បាប់នេះ។ | | គ- ទ្រព្យរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេសត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤(បួន)ឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យរូបីនោះ ត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងកាត់បន្ថយដោយចំនួនមួយស្មើនឹង ២(ពីរ)ភាគរយ នៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់។ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបី សម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធតាមមាត្រា៧ នៃច្បាប់នេះឡើយ។<br>៣- វិធាននិងនីតិវិធីនៃការធ្វើរំលស់ទ្រព្យរូបីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | ច្បាប់ថ្មី |
|---|---|
| <u>ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល</u><br>**មាត្រា១៤.. រំលស់ទ្រព្យអរូបី**<br>ចំពោះទ្រព្យអរូបី ដែលរួមមានប្រកាសនីយបត្រតក្កកម្ម សិទ្ធិចម្លង គំនូរប្លង់ គំរូ និងសិទ្ធិអាជីវកម្ម ដែលមានអាយុកាលមានកំណត់អត្រារំលស់លើទ្រព្យនីមួយៗ ត្រូវគណនាដោយផ្អែកលើអាយុកាលរបស់ទ្រព្យនោះតាមវិធីរំលស់ស្មើភាគ។ បើសិនជាអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមអត្រា ១០ភាគរយ លើតម្លៃទ្រព្យអរូបី។ | <u>ជំពូកទី២ ពន្ធលើប្រាក់ចំណូល</u><br>**មាត្រា១៤.. រំលស់ទ្រព្យអរូបី**<br>អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យអរូបី ដែលមានជាអាទិ៍ ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គំនូរឧស្សាហកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ម៉ាកឬពាណិជ្ជនាម សិទ្ធិអាជីវកម្មដែលមានអាយុកាលមានកំណត់ និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត ត្រូវធ្វើវិធីរំលស់ស្មើភាគទៅតាមអាយុកាលរបស់ទ្រព្យនីមួយៗ។ ប្រសិនបើអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមវិធីរំលស់ស្មើភាគក្នុងរយៈពេល ១០ឆ្នាំ។<br>វិធាននិងនីតិវិធីនៃការធ្វើរំលស់ទ្រព្យអរូបី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល</u><br><br>**មាត្រា១៥.. រំលស់ធនធានធម្មជាតិ**<br><br>ច្បាប់ចាស់ពុំមានចែងពីគោលការណ៍ក្នុងការរំលស់កសិកម្មរយៈពេលវែង(ទ្រព្យសកម្មជីវសាស្ត្រ) នោះទេ។ | → | <u>ជំពូកទី២ ពន្ធលើប្រាក់ចំណូល</u><br><br>**មាត្រា១៥.. រំលស់កសិកម្មនិងធនធានធម្មជាតិ**<br>១- កសិកម្មរយៈពេលវែង(ទ្រព្យសកម្មជីវសាស្ត្រ) ត្រូវប្រើវិធីរំលស់ស្មើភាគ (ដកស្រង់ពីប្រកាសស្តីពីពន្ធលើប្រាក់ចំណូល)៖<br>ក-ដំណាំកសិកម្ម៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ រួមទាំងចំណាយការប្រាក់ទាក់ទិន នឹងការអភិវឌ្ឍនិងការដាំដុះ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | ខ-ការបិញ្ជីមសត្វ៖ ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្រ្តនូវចំណាយនានាក្នុងការអភិវឌ្ឍចំណាយពាក់ព័ន្ធផ្ទាល់ជាមួយនឹងការបិញ្ជីមសត្វ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការបិញ្ជីមសត្វ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការបិញ្ជីមសត្វ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល<br><br>**មាត្រា១៨.. ការបែងចែកប្រាក់ចំណូល និងការកាត់កងក្នុងចំណោមបុគ្គលទាក់ទិន**<br>សម្រាប់គោលដៅនៃមាត្រានេះ សហគ្រាសចាប់ពី២ឡើងទៅ ត្រូវស្ថិតក្រោមកម្មសិទ្ធិរួមគ្នា [...]<br>ច្បាប់ចាស់មិនមានចែងអំពី Limited Force of Attraction ឡើយ។ | → | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br>**មាត្រា១៨.. ការបែងចែកប្រាក់ចំណូលនិងការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធ**<br>២- សម្រាប់គោលដៅនៃមាត្រានេះ៖<br>ក- សហគ្រាសចាប់ពី២ ឡើងទៅ [...]<br>ខ- ការបែងចែកប្រាក់ចំណូលទៅឱ្យគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាប់បញ្ចូលផងដែរនូវចំណូលពីការផ្គត់ផ្គង់ទំនិញឬសេវាដូចគ្នា ឬប្រហាក់ប្រហែលនឹងសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ដែលអ្នកជាប់ពន្ធ អនិវាសនជន បានផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល</u><br><br>មាត្រា២៤.. ថ្មី (ពីរ) ពន្ធអប្បបរមា<br><br>ពន្ធអប្បបរមាត្រូវកំណត់ស្មើនឹង ១ភាគរយ នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ តាមវិធានដែលមានចែងក្នុងមាត្រា៣៧ថ្មី មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់នេះ។ | → | <u>ជំពូកទី២ ពន្ធលើប្រាក់ចំណូល</u><br><br>មាត្រា២៤.. ពន្ធអប្បបរមា<br><br>ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា ១ភាគរយ លើផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានបង់ជាក់ស្តែងតាមវិធានដូចមានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណាដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។<br>លក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីក្នុងការបង់ពន្ធអប្បបរមា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | → | ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណាដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។<br>គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | ច្បាប់ថ្មី |
|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល**<br>**មាត្រា២៥.. ថ្មី ពន្ធកាត់ទុកទូទៅ**<br>ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចតទៅ៖<br>១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យដល់អ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖<br>ក- អត្រា ១៥ភាគរយ ចំពោះ៖<br>- ប្រាក់ចំណូលដែលរូបវន្តបុគ្គលបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រងឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែល<br>- សួយសារចំពោះទ្រព្យអរូបីនិងភាគកម្មក្នុងធនធានរ៉ែ ហើយនិងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលមិនមែនជាធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br>**មាត្រា២៥.. ពន្ធកាត់ទុកទូទៅ**<br>ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចខាងក្រោម៖<br>១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ ឬជាវត្ថុឱ្យអ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖<br>ក- អត្រា ១៥ភាគរយ ចំពោះ៖<br>- ប្រាក់ចំណូលដែលបុគ្គលមិនស្ថិតក្រោមរបបស្វ័យប្រកាសបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល<br>- សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ និងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មក្រៅពីធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ខ- អត្រា ១០ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនៈឬអចលនទ្រព្យ<br>គ- អត្រា ៦ ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់<br>ឃ- អត្រា ៤ ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីសន្សំគ្មានកាលកំណត់។<br>២- ការកាត់ទុកក្នុងមាត្រានេះ មិនត្រូវអនុវត្តទេចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩ថ្មី នៃច្បាប់នេះ។ | | ខ- អត្រា ១០ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនទ្រព្យ ឬអចលនទ្រព្យ<br>គ- អត្រា ៦ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់<br>ឃ- អត្រា ៤ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើគ្មានកាលកំណត់។<br>២- ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុវត្តទេ ចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល<br><br>**មាត្រា២៨.- ថ្មី ប្រាក់រំដោះពន្ធលើប្រាក់ចំណូល**<br>សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ១ភាគរយ នៃផលរបរ គិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ផលរបររបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានលើកលែងពីការបង់ប្រាក់រំដោះនេះ។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។ | → | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br><br>**មាត្រា២៨.- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល**<br>សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល មានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា ១ភាគរយ នៃផលរបររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល<br><br>**មាត្រា៣៣..ថ្មី ប្រាក់ចំណូលប្រភពកម្ពុជា**<br>៧- ផលចំណេញពីការលក់អចលនទ្រព្យ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ | ➡ | ជំពូកទី២ ពន្ធលើប្រាក់ចំណូល<br><br>**មាត្រា៣៣.. ប្រាក់ចំណូលប្រភពកម្ពុជា**<br>៧- ផលចំណេញពីការលក់ចលនទ្រព្យឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃចលន-ទ្រព្យឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស</u><br>**មាត្រា៤២.. ថ្មី និយមន័យ**<br>សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស៖<br>៤-ពាក្យ "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។<br>៥-ពាក្យ "និយោជិត" សំដៅដល់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សអំពីសកម្មភាពបម្រើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សគ្រាស មន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោតលើកលែងតែសមាជិករដ្ឋសភានិងព្រឹទ្ធសភា។ | → | <u>**ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស**</u><br>**មាត្រា៤២.. និយមន័យ**<br>សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស៖<br>៤- ពាក្យ "និយោជក" រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការ សមាគម គណបក្សនយោបាយ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។<br>៥- ពាក្យ "និយោជិត" សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សពីសកម្មភាពបម្រើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភា និងព្រឹទ្ធសភា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ៨-ពាក្យ "ប្រាក់បៀវត្ស" ក្នុងច្បាប់នេះសំដៅដល់បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។ | → | ៨- ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់ បៀវត្ស ប្រាក់ឈ្នួល លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិតឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស</u><br>**មាត្រា៤៤.- ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត**<br>ត្រូវបានលើកលែងពន្ធ៖<br>១-ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខខណ្ឌ ៣ ដូចតទៅ៖<br>២-ប្រាក់បំណាច់នៃការបញ្ឈប់លែងឱ្យធ្វើការក្នុងកម្រិតដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។<br>៣-លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ចក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ការងារ។ | | <u>ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស</u><br>**មាត្រា៤៤.- ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត**<br>ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិតត្រូវបានកំណត់ដូចខាងក្រោម៖<br>២- ប្រាក់បំណាច់នានាក្នុងករណីរំលាយកិច្ចសន្យាក្នុងកម្រិតដែលមានបញ្ញត្តិក្នុងច្បាប់ស្តីពីការងារនិងប្រភេទនៃប្រាក់បំណាច់ដែលទទួលបាននូវការលើកលែងពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>៣- លាភការបន្ថែមសម្រាប់បង្កើតបេឡាសោធននិងធានាសុខុមាលភាពសង្គម ឬមានចរិតលក្ខណៈខាងសង្គមកិច្ចក្នុងករណីដែលបានបញ្ញត្តិក្នុងច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស<br>**មាត្រា៤៥.- មូលដ្ឋានគិតពន្ធប្រចាំខែ**<br>វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨ នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយផាត់ចេញនូវ៖<br>១-ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ការងារដើម្បីបង្កើតបេឡាសោធន និងធានាសុខុមាលភាពសង្គម។<br>២-ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ។ | → | ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស<br>**មាត្រា៤៥.- មូលដ្ឋានគិតពន្ធប្រចាំខែ**<br>វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨ នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយអនុញ្ញាតឱ្យកាត់កងនូវ៖<br>១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីរបបសន្តិសុខសង្គម។<br>២- ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស</u><br><br>**មាត្រា៤៦.. ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ**<br>២- ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារនិយោជិតនិវាសនជនណាមួយដែលមាន៖<br>ក- កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ១៥០ ០០០ រៀល (មួយរយហាសិបពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ។<br>ខ- សហព័ទ្ធដែលធ្វើតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធចំនួន ១៥០ ០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់តែម្នាក់ក្នុងមួយខែ។ | → | <u>ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស</u><br><br>**មាត្រា៤៦.. ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ**<br>២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារនិយោជិតនិវាសនជនណាមួយដែលមានកូនស្ថិតក្នុងបន្ទុកនិង/ឬសហព័ទ្ធដែលធ្វើតែជាមេផ្ទះនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធតាមចំនួនដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស</u><br>**មាត្រា៤៨._ ការកំណត់ប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែម**<br>ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជក ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមកាលកំណត់តាម អត្រា ២០ភាគរយ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍ បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃ អត្ថប្រយោជន៍បន្ថែមគឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករ ទាំងអស់។ | → | <u>ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស</u><br>**មាត្រា៤៨._ ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្ស ចំពោះអត្ថប្រយោជន៍បន្ថែម**<br>ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែ និយោជក ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០ភាគរយ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់។<br>វិធាននិងនីតិវិធីនៃការលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះអត្ថប្រយោជន៍បន្ថែម ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម</u><br><br>**មាត្រា៥៩.- បុគ្គលជាប់អាករ**<br><br>ច្បាប់ចាស់មិនមានចែងអំពីបុគ្គលអនិវាសនជនដែលគ្មានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយផ្គត់ផ្គង់ទំនិញឬសេវាមកក្នុងព្រះរាជាណាចក្រកម្ពុជា។ | → | <u>**ជំពូកទី៤ អាករលើតម្លៃបន្ថែម**</u><br><br>**មាត្រា៥៨.- បុគ្គលជាប់អាករ**<br><br>សម្រាប់គោលដៅនៃមាត្រានេះ បុគ្គលអនិវាសនជន ដែលផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវចាត់ទុកជាបុគ្គលជាប់អាករ។<br><br>**មាត្រា៥៩.- ការផ្គត់ផ្គង់ជាប់អាករ**<br><br>ពាក្យ "ការផ្គត់ផ្គង់ជាប់អាករ" សំដៅដល់៖<br>១- ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>២- ការដកយកទំនិញឬសេវាមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ។<br>៣- ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ៤- ការផ្គត់ផ្គង់ទំនិញឪជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងមាត្រា៥៨ នៃច្បាប់នេះ។<br>៥- ការនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម<br><br>មាត្រា៦១.. តម្លៃជាប់អាករ<br><br>៣- តម្លៃជាប់អាករបស់ទំនិញនាំចូល គឺជាតម្លៃគយរួមបញ្ចូលទាំងតម្លៃធានារ៉ាប់រងនិងដឹកញ្ជូនដោយបូកបន្ថែមនូវពន្ធគយនិងអាករពិសេសលើទំនិញនិងសេវាមួយចំនួន។ បើសិនជាគ្មានតម្លៃគយកែតម្រូវនេះទេត្រូវកំណត់យកតាមតម្លៃទីផ្សារ។ | → | ជំពូកទី៤ អាករលើតម្លៃបន្ថែម<br><br>មាត្រា៦០.. តម្លៃជាប់អាករ<br><br>៣- តម្លៃជាប់អាករបស់ទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយរួមបញ្ចូលទាំងពន្ធគយនិងអាករនានានៅពេលនាំចូល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម**<br><br>**មាត្រា៥៧.- ការផ្គត់ផ្គង់មិនជាប់អាករ**<br>ការផ្គត់ផ្គង់មិនជាប់អាករមានដូចតទៅ៖<br>១-សេវាប្រៃសណីយ៍សាធារណៈ។<br>២-សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រនិងការលក់ទំនិញបន្ទាប់បន្សំ ខាងវេជ្ជ-សាស្ត្រនិងទន្តសាស្ត្រ ដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។<br>៣-សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។<br>៤-សេវាធានារ៉ាប់រង។ | → | **ជំពូកទី៤ អាករលើតម្លៃបន្ថែម**<br><br>**មាត្រា៦៣.- ការផ្គត់ផ្គង់មិនជាប់អាករ**<br>ការផ្គត់ផ្គង់មិនជាប់អាករមានដូចខាងក្រោម៖<br>១- សេវាសិក្សាអប់រំ។<br>២- សេវាប្រៃសណីយ៍សាធារណៈ។<br>៣-សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំ ខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។<br>៤-សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធរណៈដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ៥-សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>៦-ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ដែលរួចពន្ធគយក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>៧-សកម្មភាពមិនស្វែងរកចំណេញដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>៨- សេវាសិក្សាអប់រំ។<br>៩-ថាមពលអគ្គីសនីនិងទឹកស្អាត។<br>១០-ផលិតផលកសិកម្មមិនទាន់កែច្នៃ។ | → | ៥- សេវាធានារ៉ាប់រង។<br>៦- ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត។<br>៧- ផលិតផលកសិកម្មមិនទាន់កែច្នៃផលិតក្នុងស្រុក។<br>៨- សេវាប្រមូលសំរាម និងកាកសំណល់រឹងឬរាវ។<br>៩-សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>១០-ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម**<br>**មាត្រា៥៨.- ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូត និងអង្គការអន្តរជាតិ**<br>១- ការនាំចូលនូវទំនិញសម្រាប់ឬដោយបេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិនិងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់អំពីប្រធានបេសកកម្មជូនអគ្គនាយកដ្ឋានពន្ធដារថា ទំនិញទាំងនោះបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើនេះមែន។ | | **ជំពូកទី៤ អាករលើតម្លៃបន្ថែម**<br>**មាត្រា៦៤.- ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូត និងអង្គការអន្តរជាតិ**<br>១- ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូនរដ្ឋបាលសារពើពន្ធថា ទំនិញទាំងនោះបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើតែប៉ុណ្ណោះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ២- ការនាំចូលទំនិញសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម ឬអង្គការ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញទាំងឡាយដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | → | ២- ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញទាំងឡាយណាដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>**ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម**</u><br>**មាត្រា៦៥.- ឥណទានអាករលើធាតុចូល និងការផ្គត់ផ្គង់មិនជាប់អាករ**<br>ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចតទៅ៖<br>១-ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញ និងសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម ដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យ ឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញ ឬសេវានាំចូលសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងចេញពីអាករលើធាតុចេញ។ ធាតុចូលមានន័យថាទំនិញឬសេវា ដែលបានទិញចូល ហើយធាតុចេញមានន័យថា ទំនិញឬសេវា ដែលបានលក់ចេញ។ | | <u>**ជំពូកទី៤ អាករលើតម្លៃបន្ថែម**</u><br>**មាត្រា៦៨.- ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករ**<br>ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចខាងក្រោម៖<br>១-ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញឬសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យ ឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញឬសេវានាំចូលសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងចេញពីអាករលើធាតុចេញ។ ធាតុចូល មានន័យថា ទំនិញឬសេវាដែលបានទិញចូល ហើយធាតុចេញ មានន័យថា ទំនិញឬសេវាដែលបានលក់ចេញ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ២-ក្នុងករណីទំនិញនិងសេវា ទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ។ | → | ២-ក្នុងករណីទំនិញឬសេវាទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ។<br>៣- ចំពោះការផ្គត់ផ្គង់មិនជាប់អាករនូវទំនិញឬសេវាដល់បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងមាត្រា៦៤ នៃច្បាប់នេះ អ្នកផ្គត់ផ្គង់ត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូលដោយពុំគិតពីលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម</u><br>មាត្រា៦៨.- ឯកសារចាំបាច់សម្រាប់សុំឥណទានអាករលើធាតុចូល<br>២-ប្រតិវេទន៍គយសម្រាប់ការនាំចូលដែលអាជ្ញាធរគយបានបញ្ជាក់ត្រឹមត្រូវ។ ប្រតិវេទន៍នោះ ត្រូវមានចុះឈ្មោះបុគ្គលជាប់អាករដែលជាអ្នកទទួលទំនិញឬជាអ្នកនាំចូល និងចំនួនប្រាក់ពន្ធអាករដែលបានបង់នៅពេលនាំចូល។ | | <u>ជំពូកទី៤ អាករលើតម្លៃបន្ថែម</u><br>មាត្រា៦៩.- ឯកសារចាំបាច់សម្រាប់សុំឥណទានអាករលើធាតុចូល<br>២-ប្រតិវេទន៍គយនាំចូលដែលបានធ្វើឡើងស្របតាមច្បាប់ស្តីពីគយ និងបង្កាន់ដៃបង់ប្រាក់ពន្ធ ឬបង្កាន់ដៃបង់ប្រាក់ផ្សេងៗរបស់រដ្ឋបាលគយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម<br>**មាត្រា៧៧.- វិក្កយបត្រអាករលើតម្លៃបន្ថែម**<br>គោលការណ៍ស្តីពីវិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចតទៅ៖<br>១-បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអាករលើតម្លៃបន្ថែមដែលមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញ។ | | ជំពូកទី៤ អាករលើតម្លៃបន្ថែម<br>**មាត្រា៧៨.- វិក្កយបត្រអាករលើតម្លៃបន្ថែម**<br>វិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចខាងក្រោម៖<br>១-បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអាករ ដោយមានដាក់ចំណងជើងថា “វិក្កយបត្រអាករ” ហើយមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវចេញវិក្កយបត្រធម្មតាទៅឱ្យអ្នកទិញដែលមិនស្ថិតនៅក្រោមរបបស្វ័យប្រកាស។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **<u>ជំពូកទី៣ បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម</u>**<br>**មាត្រា៧៩.. បញ្ជី កំណត់ត្រា និងព័ត៌មាន**<br>គោលការណ៍ស្តីពីបញ្ជីកំណត់ត្រាព័ត៌មានសម្រាប់អាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចតទៅៈ<br>១-សម្រាប់គោលដៅបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកនេះ បុគ្គលជាប់អាករត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានធ្វើចេញនិងវិក្កយបត្រទាំងអស់ដែលបានទទួល។<br>៥-ឯកសារនិងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ហើយនិងឯកសារនិងកំណត់ត្រាឯទៀតដែលទាក់ទងនឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្តល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានសំណើ។ | ➡ | **<u>ជំពូកទី៤ អាករលើតម្លៃបន្ថែម</u>**<br>**មាត្រា៨០.. បញ្ជី កំណត់ត្រា និងព័ត៌មាន**<br>បញ្ជី កំណត់ត្រា និងព័ត៌មានសម្រាប់អាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចខាងក្រោមៈ<br>១-បុគ្គលជាប់អាករ ត្រូវប្រើប្រាស់ប្រព័ន្ធកត់ត្រាសាច់ប្រាក់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានចេញ និងវិក្កយបត្រទាំងអស់ដែលបានទទួល។<br>៥- ប្រព័ន្ធកត់ត្រាសាច់ប្រាក់ ឯកសារ និងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ព្រមទាំងឯកសារនិងកំណត់ត្រាឯទៀតដែលទាក់ទិននឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្តល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានការស្នើសុំ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៦ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ</u><br><br>មាត្រា១៥០.. ការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត អាជ្ញាបណ្ណឬកិច្ចព្រមព្រៀងធនធានរ៉ែ | → | <u>ជំពូកទី១០ ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ</u><br><br>មាត្រា១៣៤.. ការផ្ទេរអត្ថប្រយោជន៍និងការអភិវឌ្ឍនិងផលិតកម្មរួម<br><br>២- ចំពោះអ្នកជាប់ពន្ធពីរ ឬច្រើនដែលត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងអភិវឌ្ឍន៍និងផលិតកម្ម រួមដើម្បីធ្វើប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតមួយ ឬច្រើនដែលស្ថិតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតផ្សេងគ្នា វិធាននិងនីតិវិធីដែលត្រូវអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្ដីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា៨៨.- និយមន័យ**<br>ច្បាប់ចាស់មិនមានចែងអំពីនិយមន័យនៃមន្ត្រីពន្ធដា ការស៊ើបអង្កេតឡើយ ពន្ធបន្ថែម និងការប្រាក់ឡើយ។ | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា១៩០.- និយមន័យ**<br>៥- មន្ត្រីពន្ធដារ សំដៅដល់មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ដែលកំពុងបម្រើការងារក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋានពន្ធដារ។<br>៦- ការស៊ើបអង្កេត សំដៅដល់ ការធ្វើសវនកម្មពន្ធដារគ្រប់ប្រភេទ រួមទាំងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។<br>១០- ពន្ធបន្ថែម សំដៅដល់ ទណ្ឌកម្មជាសាច់ប្រាក់ចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្ដីពីពន្ធដារ ដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | ១១- ការប្រាក់ សំដៅដល់ ការប្រាក់ដែលកើតឡើងពីការបង់ពន្ធខ្វះឬការបង់ពន្ធយឺតដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៩ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា៨៩._ កិច្ចព្រមព្រៀងអន្តរជាតិ<br>បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ។ | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១៩១._ កិច្ចព្រមព្រៀងអន្តរជាតិ<br>បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធដែលរដ្ឋសភាបានផ្តល់សច្ចាប័ន ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ។<br>វិធាននិងនីតិវិធីសម្រាប់អនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រម-ព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្ដីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា៩២.- អំណាច និងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ<br>អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ៖[...] | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១៩៤.- អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ<br>អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖<br>១- រដ្ឋបាលសារពើពន្ធមានអំណាចដូចខាងក្រោម៖<br>ឈ- ច្រានចោល និង/ឬកំណត់សារជាតុពិតនៃប្រតិបត្តិការទាំងឡាយឡើងវិញក្នុងករណីពិនិត្យឃើញថាអ្នកជាប់ពន្ធបានរៀបចំ ឬមានប្រតិបត្តិការទាំងឡាយណាដែលបង្ហាញធន្ទៈមិនពិត ឬគ្មានភាពជាក់ស្ដែងក្នុងគោលបំណងដើម្បីបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលត្រូវបង់ដែលផ្ទុយពីស្មារតីនៃបទប្បញ្ញត្តិស្ដីពីពន្ធដារ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>**ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**</u><br>**មាត្រា៩៣_ ការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ពន្ធដារ**<br>ស្ថាប័នទាំងឡាយដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ មានដូចខាងក្រោម៖<br>-អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ។<br>រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទោសទណ្ឌតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការក្នុងករណីមានការរំលោភច្បាប់។ | → | <u>**ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ**</u><br>**មាត្រា១៩៥_ ស្ថាប័នមានសមត្ថកិច្ច**<br>១-ស្ថាប័នដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម៖<br>ក-អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ខ-ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ។<br>២- រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទណ្ឌកម្មតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការក្នុងករណីមានការរំលោភច្បាប់។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ៣- រដ្ឋបាលសារពើពន្ធគឺជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល។ ការសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាល ជាសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលសារពើពន្ធអាចសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាលនេះបាន ក្នុងករណីទទួលបានការធ្វើប្រតិភូកម្មសិទ្ធិអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា៩៥_ថ្មី ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ**<br>១-លិខិតស្នាមឬលិខិតជូនដំណឹង ដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធ មានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយ លក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ។ | → | **ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា១៩៨_ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ**<br>ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធត្រូវអនុវត្តដូចខាងក្រោម៖<br>១- លិខិតស្នាមឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធមានលក្ខណៈ ជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ។ លិខិតស្នាមឬលិខិតជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌនេះ រួមបញ្ចូលទាំងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដែលក្នុងនោះ មានជាអាទិ៍ទូរសារ សារអេឡិចត្រូនិក។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារ តម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាមឬដំណឹងជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គល លិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវលុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ។ | → | ២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាមឬលិខិតជូនដំណឹងទៅឱ្យបុគ្គល លិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវលុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ។ ចំពោះការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានចាត់ទុកថាបានប្រគល់ត្រឹមត្រូវ ប្រសិនបើបានបញ្ជូនទៅអាសយដ្ឋានចុងក្រោយដែលអ្នកជាប់ពន្ធបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ឥ)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **<u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u>**<br><br>**មាត្រា៩៩_ថ្មី សិទ្ធិទទួលព័ត៌មាន**<br><br>អំណាចរបស់រដ្ឋបាលសារពើពន្ធមានដូចខាងក្រោមនេះ៖<br><br>៤- ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធ ឬភ្នាក់ងារគាត់ទុក ដូចមានចែងក្នុងមាត្រា៩៩ ថ្មីនៃច្បាប់នេះ។ | → | **<u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u>**<br><br>**មាត្រា២០២_ សិទ្ធិទទួលព័ត៌មាន**<br><br>៣- អ្នកជាប់ពន្ធឬតតិយជន រួមទាំង ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបញ្ជូនរបាយការណ៍ឬបញ្ជូនលិខិតឆ្លើយតបមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ។<br><br>៤- បុគ្គលទាំងឡាយអាចរាយការណ៍មករដ្ឋបាលសារពើពន្ធនូវព័ត៌មានដែលពាក់ព័ន្ធនឹងពន្ធដារ។<br><br>៥- ការសម្ងាត់វិជ្ជាជីវៈមិនត្រូវបានរាំងដល់ការអនុវត្តមាត្រានេះ និងមាត្រាដទៃទៀតនៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
| --- | --- | --- |
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា១០១.. កាតព្វកិច្ចចុះបញ្ជី**<br>បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។<br>បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។ | | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា២០៣.. កាតព្វកិច្ចចុះបញ្ជីនិងបច្ចុប្បន្នភាព**<br>១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័ន ឬអង្គការនានា ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា៥ នៃច្បាប់នេះ។<br>២-បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។<br>វិធាននិងនីតិវិធីនៃការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៩ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ<br><br>មាត្រា១០៤_ថ្មី ការរៀបចំនិងដាក់លិខិតប្រកាសពន្ធ<br><br>ច្បាប់ចាស់មិនមានកំណត់ពីតម្លៃស្មើគ្នានៃការដាក់លិខិតប្រកាសសារពើពន្ធជាលាយលក្ខណ៍អក្សរ និងលិខិតប្រកាសអេឡិចត្រូនិក។ | → | ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ<br><br>មាត្រា២០៦_ការដាក់លិខិតប្រកាសសារពើពន្ធ<br><br>៥- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ឬអ្នកវិនិយោគទាំងអស់ អាចដាក់លិខិតប្រកាសសារពើពន្ធដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះ តាមប្រព័ន្ធទទួលលិខិតប្រកាសអេឡិចត្រូនិករបស់រដ្ឋបាលសារពើពន្ធ ហើយមានតម្លៃស្មើគ្នានឹងលិខិតប្រកាសសារពើពន្ធជាលាយលក្ខណ៍អក្សរដែលជាច្បាប់ដើម។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្ដីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១១៧_ ការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញ<br>ការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញ ត្រូវដំណើរការដូចតទៅ៖[...] | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា២១០_ ការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញ<br>ការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញ ត្រូវដំណើរការដូចខាងក្រោម៖[...]<br>៦-វិធាននិងនីតិវិធីនៃការកំណត់ពន្ធឡើងវិញ និងរយៈពេលកំណត់ពន្ធឡើងវិញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ<br>មាត្រា១០៧.- ការបង់ពន្ធ | → | ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ<br>មាត្រា២១៣.- ការបង់ពន្ធ<br>៥- អាជ្ញាយុកាលនៃការលត់សិទ្ធិលើបំណុលពន្ធមានរយៈពេល ១០ឆ្នាំចាប់ពីថ្ងៃដែលបំណុលពន្ធត្រូវបានជូនដំណឹងទៅអ្នកជាប់ពន្ធ។ វិធាននិងនីតិវិធីនៃការផ្អាក ឬបង្អង់អាជ្ញាយុកាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ឥ)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១០៩_សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ<br>នៅក្នុងច្បាប់ចាស់ សិទ្ធិលើបំណុលរបស់រដ្ឋបាលសារពើពន្ធមានអាទិភាពមុនគេដោយមិនមានផ្សព្វផ្សាយជាមុននោះឡើយ។ | ➡ | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា២១៧_ ***សិទ្ធិឃាត់ទុក ចាប់យក និង***ឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ<br>៣- បើលក្ខខណ្ឌទាំងឡាយនៃមាត្រានេះត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ មានសុពលភាពនិងអាទិភាពលើសិទ្ធិដទៃទៀតទាំងអស់ ដែលមានពីមុនមក ឬដែលកើតឡើងក្រោយសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យ សម្បត្តិរបស់អ្នកជាប់ពន្ធ លើកលែងតែមានការកំណត់ផ្ទុយពីនេះក្នុងច្បាប់ស្តីពីក្ស័យធននិងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិប្រាតិភោគ។ រដ្ឋបាលសារពើពន្ធ ត្រូវធ្វើសេចក្តីប្រកាសផ្សាយជាសាធារណៈអំពីទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | រាល់សិទ្ធិប្រាតិភោគដែលត្រូវបានបង្កើតឡើងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធនៅក្រោយកាលបរិច្ឆេទនៃការប្រកាសផ្សាយជាសាធារណៈរបស់រដ្ឋបាលសារពើពន្ធ មិនអាច យកមកតតាំងជាមួយនឹងសិទ្ធិអាទិភាពរបស់រដ្ឋបាលសារពើពន្ធលើទ្រព្យសម្បត្តិនោះបានឡើយ។ បែបបទនិងនីតិវិធីនៃការប្រកាសផ្សាយជាសាធារណៈនូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br><br>មាត្រា១១១.. ការរឹបអូស<br><br>ច្បាប់ចាស់អនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធរឹបអូសដោយមិនចាំបាច់មានការសម្រេចពីតុលាការ។ | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br><br>មាត្រា២១៨.. **សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្តោះអាសន្ន និងការរឹបអូស**<br><br>សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្តោះអាសន្ន និងការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖<br><br>១-ក្នុងករណីចាំបាច់ និងដើម្បីធានានូវការទូទាត់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវបានឃាត់ទុក។<br><br>២- ក្រៅពីសិទ្ធិប្រើប្រាស់និងអាស្រ័យផលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋបាលសារពើពន្ធអាចប្តឹងទៅតុលាការដើម្បីរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធក្នុងគោលដៅធានាការទូទាត់បំណុលពន្ធ។ ក្នុងអំឡុងពេលដែលមិនទាន់មានសេចក្តីសម្រេចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធជាស្ថាពរនិងក្នុងករណីដែលទទួលបានការអនុញ្ញាតតាមដីកាសម្រេចពីតុលាការដែលទទួលពាក្យបណ្តឹង |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ឥ)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | រដ្ឋបាលសារពើពន្ធអាចធ្វើការចាត់ចែងជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធក្នុងទម្រង់ជាការលក់ឡាយឡុង ហើយប្រាក់ដែលបានមកពីការចាត់ចែងជាបណ្តោះអាសន្នត្រូវរក្សាទុកនៅក្នុងគណនីបណ្តោះអាសន្នមួយរបស់រដ្ឋបាលសារពើពន្ធ។<br>៣- បុគ្គលដែលមានភារៈកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវរដ្ឋបាលសារពើពន្ធរឹបអូសដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅឱ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត។<br>៤- ចំពោះទ្រព្យសម្បត្តិជាសាច់ប្រាក់ រដ្ឋបាលសារពើពន្ធអាចរឹបអូសសាច់ប្រាក់របស់អ្នកជាប់ពន្ធ ឬសាច់ប្រាក់ដែលអ្នកជាប់ពន្ធនឹងត្រូវទទួលបាន ដោយមិនចាំបាច់អនុវត្តតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្ដីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល(ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្ដីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១១២_កិច្ចគាំពារអ្នកជាប់ពន្ធ<br>ទ្រព្យសម្បត្តិដែលត្រូវរឹបអូសដោយច្បាប់នេះ ត្រូវរឹបអូស កាន់កាប់ និងទទួលខុសត្រូវដោយរដ្ឋបាលសារពើពន្ធតែប៉ុណ្ណោះ។ ស្ថាប័នផ្សេងរបស់រាជរដ្ឋាភិបាលមិនអាចប្រើច្បាប់នេះដើម្បីរឹបអូស ឬកាន់កាប់ទ្រព្យសម្បត្តិនោះដោយផ្ទាល់ឡើយ។ បើមានការលក់នូវទ្រព្យសម្បត្តិដែលបានរឹបអូសដោយច្បាប់នេះ ចំណែកណាមួយនៃប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅឱ្យម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិនោះវិញ។ | → | <u>ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា២១៩_ការចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូស<br>ក្នុងករណីដែលមានការលក់នូវទ្រព្យសម្បត្តិបន្ទាប់ពីមានការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ចំនួនទឹកប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅឱ្យអ្នកជាប់ពន្ធវិញ លើកលែងតែមានការចាត់ចែងផ្សេងពីនេះដោយតុលាការស្របតាមច្បាប់ជាធរមាន។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល(ឥ)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា១១៣.. ការឃាត់ទុកគណនីធនាគារ**<br>ការរឹបអូសក្នុងមាត្រា១១១ នៃច្បាប់នេះ អាចមានទាំងការឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារ តាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ។<br>តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតឱ្យអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យ ដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ការប្រាក់ ហើយនិងពន្ធបន្ថែមផ្សេងទៀត។ | ➡ | **ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា២២០.. ការឃាត់ទុកគណនីធនាគារ**<br>១- រដ្ឋបាលសារពើពន្ធអាចឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ។ ការឃាត់ទុកគណនីធនាគារក្នុងមាត្រានេះរួមបញ្ចូលទាំងការឃាត់ទុកប្រតិបត្តិការតាមគ្រប់ទម្រង់។<br>២-តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀត ឱ្យអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ពន្ធបន្ថែមការប្រាក់ និងការផាកពិន័យជាប្រាក់ផ្សេងទៀត។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល(ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ<br><br>មាត្រា១១៥.. ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ<br><br>ការរឹបអូសក្នុងមាត្រា១១១ នៃច្បាប់នេះ អាចមានទាំងការចេញលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធដើម្បីអនុវត្តសកម្មភាពណាមួយ។ | ➡ | ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ<br><br>មាត្រា២២១..ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ<br><br>រដ្ឋបាលសារពើពន្ធអាចចេញលិខិតជូនដំណឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធ ដើម្បីអនុវត្តសកម្មភាពណាមួយ។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល(ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
| --- | --- | --- |
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា១២៨.- អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ**<br>អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ រួមមាន៖<br>១-ករណីដែលបុគ្គល៖<br>ក-មិនបានរក្សាបញ្ជិកាគណនេយ្យនិងឯកសារផ្សេងទៀត ឬមិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ<br>ខ-មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជិកាគណនេយ្យឬឯកសារផ្សេងៗ<br>គ-មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ<br>ឃ-មិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី ដូចមានចែងក្នុងច្បាប់នេះ | | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២២៥.- អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ**<br>ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអំពើដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ដូចខាងក្រោម៖<br>១-ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។<br>២-ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ អំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។<br>៣- ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ ។<br>៤-ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល(ឥ)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ង-កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ<br>ច-លាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជីគណនេយ្យ កំណត់ត្រាឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗទៀត<br>ឆ-ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ<br>ជ-មិនបានដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ពន្ធត្រូវបង់ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទដែលច្បាប់បានកំណត់<br>ឈ-ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ។<br>២-ករណីដែលមន្ត្រីរាជការ៖<br>ក-ធ្វើឱ្យធ្លាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត<br>ខ-ព្យាយាមធ្វើឱ្យរាំងស្ទះដល់ការកំណត់និងការប្រមូលពន្ធ<br>គ-ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ។ | ➡ | ៥- ការមិនបានចេញវិក្កយបត្រ។<br>៦- ការមិនផ្តល់ព័ត៌មាន ឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។<br>៧- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជិកាគណនេយ្យ ឬឯកសារផ្សេងៗ។<br>៨- ការមិនបានរក្សាបញ្ជិកាគណនេយ្យ និងឯកសារផ្សេងទៀត។<br>៩- ការព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ។<br>១០-ការកសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។<br>១១-ការលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។<br>១២-ការចេញវិក្កយបត្រក្លែងបន្លំ។<br>១៣- ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។ |

# ២- រចនាសម្ព័ន្ធនៃច្បាប់ស្តីពីសារពើពន្ធ និងខ្លឹមសារនៃការកែសម្រួល (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា១២៧_ការគេចវេះពន្ធ**<br>ការគេចវេះពន្ធ គឺជាបទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុកនិងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្លំ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។<br>ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរ ក្នុងករណីដែលការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់នេះ បានប្រព្រឹត្តឡើង៖<br>១-ពីរលើកដាច់ពីគ្នា ក្នុងរយៈពេល ៣ឆ្នាំ នៃឆ្នាំប្រតិទិន។<br>២-បីលើកឬច្រើនជាងនេះដាច់ពីគ្នា ក្នុងរយៈពេលណាមួយក៏ដោយ។ | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២២៦_ការគេចវេះពន្ធ**<br>១- ការគេចវេះពន្ធ គឺជាអំពើណាមួយដែលបានប្រព្រឹត្តឡើងដោយចេតនានិងមានការរៀបចំទុកជាមុនដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។<br>២- ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖<br>ក-ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំនៃឆ្នាំប្រតិទិន។<br>ខ-ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងបីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល ១០(ដប់)ឆ្នាំ នៃឆ្នាំប្រតិទិន។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>**ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**</u><br>**មាត្រា១៣៤.- អំណាចក្នុងការប្តឹងចោទប្រកាន់ខាងបទព្រហ្មទណ្ឌ**<br>លើកលែងតែចំពោះបទល្មើសមានចែងនៅក្នុងមាត្រា ១៣៩ និងមាត្រា១៤០ នៃច្បាប់នេះ ការប្តឹងចោទប្រកាន់ និងទាមទារការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងដោយអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | → | <u>**ជំពូកទី១៨ ទោសប្បញ្ញត្តិ**</u><br>**មាត្រា២២៨.- សមត្ថកិច្ចក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌ**<br>១- រដ្ឋបាលសារពើពន្ធជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងការកសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមច្បាប់នេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។<br>២- រដ្ឋបាលសារពើពន្ធ ក៏អាចមានសមត្ថកិច្ចផងដែរក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតដែលមានការពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រសិនបើមានការអនុញ្ញាតពីព្រះរាជអាជ្ញា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១០០.- អំណាចក្នុងការស៊ើបអង្កេត<br>ចំពោះមុខ សម្រាប់ការស៊ើបអង្កេតនីមួយៗដោយមានលិខិតបញ្ជាបេសកកម្ម រដ្ឋបាលសារពើពន្ធមានសិទ្ធិចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ទីកន្លែងដែលបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ជាកន្លែងដែលបើកជាសាធារណៈ ឬទីកន្លែងដទៃទៀត ដើម្បីធ្វើការកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ឬដើម្បីប្រមូលពន្ធ៖<br>- នៅក្នុងពេលម៉ោងអាជីវកម្ម<br>- នៅគ្រប់ពេលទាំងអស់ស្របតាមលក្ខខណ្ឌ និងហេតុផលដែលមានបញ្ជាក់នៅក្នុងដីកាដែលចៅក្រមបានចេញឱ្យ។ | ➡ | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>មាត្រា២៣០.- អំណាចក្នុងការស៊ើបអង្កេត<br>១- មន្ត្រីពន្ធដារមានអំណាចចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បីពិនិត្យបញ្ជីគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដើម្បីកំណត់ពន្ធ។ ការចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងនៅក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលា ដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការឬស្ថាប័នតុលាការ ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ២- មន្ត្រីពន្ធដារដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ដូចដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ មានសិទ្ធិ៖<br>ង-ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីធានាបំណុលពន្ធ<br>ច-ឃាត់ខ្លួនអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| កថាខណ្ឌ៣ ត្រូវបានស្នើសុំដោយMOJ និងមិនមានចែងនៅក្នុងច្បាប់ចាស់នោះទេ។ | ➡ | ៣- ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានរកឃើញនៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់មន្ត្រីពន្ធដារ ប្រតិបត្តិការរបស់មន្ត្រីពន្ធដារទាក់ទិននឹងការប្រមូលភស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តរាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផង ត្រូវធ្វើឡើងដោយមន្ត្រីពន្ធដារដែលមាននីតិសម្បទាជាមន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា១៣០._ពន្ធបន្ថែម**<br>ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ។<br>ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះឬការបង់យឺត ត្រូវគណនាដាច់ដោយឡែកពីពន្ធបន្ថែមសម្រាប់ការរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។<br>ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែមនិងការប្រាក់ត្រូវដល់កំណត់និងត្រូវបង់តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ។<br>ទោះជាក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តទោសទណ្ឌចំពោះបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ។ | → | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៣២._ការអនុវត្តពន្ធបន្ថែម**<br>១- ពន្ធបន្ថែមត្រូវអនុវត្ត ចំពោះអំពើល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ។<br>២- ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះ ឬការបង់យឺតត្រូវគណនាដាច់ដោយឡែកពីការផាកពិន័យជាប្រាក់ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។<br>៣- ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែម និងការប្រាក់ត្រូវដល់កំណត់ និងត្រូវបង់តាមបែបបទដូចប្រាក់ពន្ធដែលបានបង់ខ្វះនោះ។<br>៤-ទោះបីក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្ត ទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>មាត្រា១៣៣_ ពន្ធបន្ថែមចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ<br>ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ពន្ធបន្ថែមត្រូវកំណត់ដូចខាងក្រោមនេះ សម្រាប់អំពើនីមួយៗ៖<br>១- ២ ០០០ ០០០ រៀល (ពីរលានរៀល) ចំពោះបុគ្គល អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកក្រោមរបបស្វ័យប្រកាស ឬ មន្ត្រីរាជការ។<br>២- ៥០០ ០០០ រៀល (ប្រាំសែនរៀល) ចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកក្រោមរបបបំព្រួញ ឬរបបម៉ៅការ។ | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>មាត្រា២៣៥_ ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ<br>ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានកំណត់ដូចខាងក្រោម៖<br>១- ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន) រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មផ្នែករដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលធ្លាប់ត្រូវបានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីរដ្ឋបាល-សារពើពន្ធលើសពីពីរលើក ហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១ កថាខណ្ឌ២ និងកថាខណ្ឌ៣ នៃមាត្រា២២៥ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | ២- ត្រូវផាកពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន) រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មផ្នែករដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌ៤ កថាខណ្ឌ៥ កថាខណ្ឌ៦ កថាខណ្ឌ៧ និងកថាខណ្ឌ៨ នៃមាត្រា២២៥ នៃច្បាប់នេះ។ |
| | → | ៣- ក្នុងករណីដែលបុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ផាកពិន័យដូចមានចែងក្នុងកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រានេះ រួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១ កថាខណ្ឌ២ កថាខណ្ឌ៣ កថាខណ្ឌ៤ កថាខណ្ឌ៥ កថាខណ្ឌ៦ កថាខណ្ឌ៧ និងកថាខណ្ឌ៨ នៃមាត្រា២២៥ នៃច្បាប់នេះ  ម្តងទៀត បុគ្គលនោះត្រូវមានទោសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា២៤៣ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**<br>**មាត្រា១២០.-វិធាននៃបណ្តឹងតវ៉ាខាងរដ្ឋបាល**<br>វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវបានកំណត់ដូចតទៅ៖<br>១-អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ពន្ធឡើងវិញឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយរដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេច ឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។ | ➡ | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៣៦.-វិធាននៃបណ្តឹងតវ៉ាខាងរដ្ឋបាល**<br>វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖<br>១-អ្នកជាប់ពន្ធដែលមិនយល់ព្រមនឹងការកំណត់ពន្ធឡើងវិញ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាល-សារពើពន្ធ អាចធ្វើការតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេច ឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ២-ការតវ៉ាខាងរដ្ឋបាលត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដែលមានចែងនៅក្នុងមាត្រា១២១ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ។<br><br>៣-ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ។ | → | ២- ការតវ៉ាខាងរដ្ឋបាល ត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដូចមានចែងនៅក្នុងមាត្រា២៣៦ នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត ៣០ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។<br><br>៣-ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធឡើយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br><br>**មាត្រា១២៣.- គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ**<br><br>ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្រុះ-សម្រួលសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br><br>**មាត្រា២៣៩.- គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ**<br><br>១- គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ មានភារកិច្ចពិនិត្យដោះស្រាយលើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងវិវាទពន្ធដារ។<br><br>២- ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **<u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u>**<br>**មាត្រា១២៤._បណ្តឹងទៅតុលាការ**<br>អ្នកជាប់ពន្ធ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះ-សម្រួលសារពើពន្ធក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។<br>អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅធនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលទាក់ទិននឹងវិវាទតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ | | **<u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u>**<br>**មាត្រា២៤០._បណ្តឹងទៅតុលាការ**<br>១- អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត ៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។<br>២- អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅធនាគារជាតិនូវប្រាក់ *ឬទ្រព្យដែលមានតម្លៃសមមូលយ៉ាងតិចស្មើនឹងចំនួនប្រាក់ពន្ធ* ដែលទាក់ទិននឹងវិវាទ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ *វិធាន និងនីតិវិធីនៃ ការកំណត់ និងការដាក់ប្រាក់តម្កល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។* |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ**<br><br>**មាត្រា១៣៥._ការគេចវេះពន្ធ**<br><br>ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬ បុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបាន ប្រព្រឹត្តអំពើគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ រៀល (ដប់លានរៀល) ដល់ ២០ ០០០ ០០០ រៀល (ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ឬទោសទាំងពីរនេះ។ | → | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br><br>**មាត្រា២៤២._បទល្មើសគេចវេះពន្ធ**<br><br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណា មួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែល បានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា២២៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ដល់ ២០០ ០០០ ០០០ (ពីររយលាន)រៀល។ |

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ<br><br>**មាត្រា១៣៦.- អំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ**<br><br>ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ដល់ ១០ ០០០ ០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។ | → | ជំពូកទី១៨ ទោសប្បញ្ញត្តិ<br><br>**មាត្រា២៤៣.- បទល្មើសរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ**<br><br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចខាងក្រោម៖<br><br>១- ព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ២- កសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។<br>៣-លាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណ-នេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ឬ ព័ត៌មានផ្សេងៗ។<br>៤-ចេញវិក្កយបត្រក្លែងបន្លំ។<br>៥-មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ខ- ចំនួនមាត្រាដែលត្រូវបានធ្វើការកែសម្រួលខ្លឹមសារនិងបន្ថែមខ្លឹមសារ (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៥ បទប្បញ្ញត្តិស្តីពីវិធាននិងនីតិវិធីសារពើពន្ធ</u><br>**មាត្រា១៣៨.- ការធ្វើឱ្យធ្លាយការសម្ងាត់**<br>ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានបំពានមាត្រា៩៤ នៃច្បាប់នេះ ត្រូវជាប់ពិរុទ្ធអំពីបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ដល់ ១០ ០០០ ០០០ រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។ | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២៤៤.- ការធ្វើឱ្យធ្លាយការសម្ងាត់នៃព័ត៌មានពន្ធដារ**<br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលណាដែលបានធ្វើឱ្យធ្លាយការសម្ងាត់នៃព័ត៌មានពន្ធដារដោយបំពានមាត្រា១៩៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ដល់ ១០០ ០០០ ០០០ (មួយរយលាន) រៀល។ |

## ២.២. មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា

### គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង៖ ៦១មាត្រា

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី១ បទប្បញ្ញត្តិទូទៅ (២មាត្រា) | មាត្រា១, មាត្រា២ |
| ជំពូកទី២ ពន្ធលើប្រាក់ចំណូល (១មាត្រា) | មាត្រា៣ |
| ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស (១មាត្រា) | មាត្រា៥៤ |
| ជំពូកទី៤ អាករលើតម្លៃបន្ថែម (៤មាត្រា) | មាត្រា៥៥, មាត្រា៥៦, មាត្រា៧៥, មាត្រា៨៤ |
| ជំពូកទី៥ អាករពិសេស (៧មាត្រា) | មាត្រា៨៥, មាត្រា៨៦, មាត្រា៨៧, មាត្រា៨៨, មាត្រា៨៩, មាត្រា៩០, មាត្រា៩១ |
| ជំពូកទី៦ អាករសម្រាប់បំភ្លឺសាធារណៈ (៣មាត្រា) | មាត្រា៩៥, មាត្រា៩៦, មាត្រា៩៩ |
| ជំពូកទី៧ អាករលើការស្នាក់នៅ (២មាត្រា) | មាត្រា១០៥, មាត្រា១០៧ |
| ជំពូកទី៨ ពន្ធប៉ាតង់ (៣មាត្រា) | មាត្រា១១០, មាត្រា១១១, មាត្រា១១៥ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី៩ ពន្ធលើផ្ទាំងផ្សព្វផ្សាយ (៣មាត្រា) | មាត្រា១១៦, មាត្រា១១៧, មាត្រា១២៣ |
| ជំពូកទី១០ ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ (២មាត្រា) | មាត្រា១២៤, មាត្រា១៣៨ |
| ជំពូកទី១១ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ (១មាត្រា) | មាត្រា១៤៦ |
| ជំពូកទី១២ ពន្ធលើអចលទ្រព្យ (២មាត្រា) | មាត្រា១៤៧, មាត្រា១៥៤ |
| ជំពូកទី១៣ ពន្ធប្រថាប់ត្រា (២មាត្រា) | មាត្រា១៥៥, មាត្រា១៦៤ |
| ជំពូកទី១៤ ពន្ធលើចំណេញមូលធន (២មាត្រា) | មាត្រា១៦៥, មាត្រា១៧២ |
| ជំពូកទី១៥ ពន្ធលើដីធ្លីមិនប្រើប្រាស់ (៤មាត្រា) | មាត្រា១៧៤, មាត្រា១៧៨, មាត្រា១៧៩, មាត្រា១៨០ |
| ជំពូកទី១៦ ពន្ធលើមធ្យោបាយដឹកជញ្ជូន (៧មាត្រា) | មាត្រា១៨១, មាត្រា១៨២, មាត្រា១៨៣, មាត្រា១៨៤, មាត្រា១៨៥, មាត្រា១៨៧, មាត្រា១៨៨ |

## ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

### គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី១៧ វិធាននិងនីតិវិធីសារពើពន្ធ(២មាត្រា) | មាត្រា១៩៦, មាត្រា២១៥ |
| ជំពូកទី១៨ ទោសប្បញ្ញត្តិ (១២មាត្រា) | មាត្រា២២៧, មាត្រា២៣១, មាត្រា២៣៤, មាត្រា២៤១, មាត្រា២៤៥, មាត្រា២៤៦, មាត្រា២៤៧, មាត្រា២៤៨, មាត្រា២៤៩, មាត្រា២៥០, មាត្រា២៥១, មាត្រា២៥២ |
| ជំពូកទី១៩ អន្តរប្បញ្ញត្តិ(១មាត្រា) | មាត្រា២៥៣ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

ក្នុងចំណោម ៦១មាត្រា មាន ៣០មាត្រាចែងអំពី(១) គោលបំណង (២) វិសាលភាព (៣) កម្មវត្ថុនៃពន្ធ និង (៤) វិធាននិងនីតិវិធីនៃការប្រមូលពន្ធអាករ ឱ្យស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

*ដកស្រង់យក ៣១មាត្រា

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| <u>ជំពូកទី៣ បទប្បញ្ញត្តិស្ដីពីអាករលើតម្លៃបន្ថែម</u> | → | <u>ជំពូកទី៤ អាករលើតម្លៃបន្ថែម</u><br>**មាត្រា៧៥._ ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់**<br>ការផ្គត់ផ្គង់ធាតុចូលផលិតកម្មក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្តគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា 0ភាគរយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **<u>ជំពូកទី៥ អាករពិសេស</u>**<br>**មាត្រា៨៧.- និយមន័យ**<br>សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីអាករពិសេស៖<br>១- ពាក្យ "បុគ្គលជាប់អាករពិសេស" សំដៅដល់ អ្នកនាំចូល ឬ អ្នកផលិតទំនិញ ឬអ្នកផ្គត់ផ្គង់សេវាជាប់អាករពិសេស។<br>២- ពាក្យ "ការនាំចូល" សំដៅដល់ សកម្មភាពនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលណាមួយ។<br>៣- ពាក្យ "អ្នកនាំចូល" សំដៅដល់ បុគ្គលណាមួយដែលធ្វើការនាំចូលដោយខ្លួនឯង ឬដោយបុគ្គលដទៃ។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ អ្នកទទួលទំនិញ បុគ្គលជាម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងទៅជាម្ចាស់កម្មសិទ្ធិ ឬអ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិញមុនពេលដែលទំនិញនោះឈប់ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ត្រូវបានចាត់ទុកថាជាអ្នកនាំចូលដែរ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | ៤- ពាក្យ "ការផលិត" សំដៅដល់ សកម្មភាពបំប្លែងវត្ថុធាតុដើម ផ្គុំ ដំឡើង វេចខ្ចប់ ប្រកបំពេញឱ្យទៅជាផលិតផលពាក់កណ្ដាលសម្រេចឬផលិតផលសម្រេច។<br>៥- ពាក្យ "អ្នកផលិត" សំដៅដល់ បុគ្គលណាមួយដែលធ្វើការផលិតទំនិញ ឬបុគ្គលណាមួយដែលជួលបុគ្គលដទៃទៀតផលិតទំនិញឱ្យខ្លួន។<br>៦- ពាក្យ "អ្នកចែកចាយ" សំដៅដល់ បុគ្គលដែលធ្វើការផ្គត់ផ្គង់ទំនិញដែលនាំចូល ឬផលិតដោយខ្លួនឯង ឬទិញបន្តពីអ្នកនាំចូល ឬពីអ្នកផលិត។<br>៧- ពាក្យ "ការផ្គត់ផ្គង់" សំដៅដល់ ការលក់ ឬការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការផ្ដល់ជាអំណោយ ឬការលក់ក្រោមតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករពិសេស។<br>៨- ពាក្យ "តែមប្រើអាករ" សំដៅដល់ សន្លឹកតែមប្រើសម្រាប់បិទលើទំនិញជាប់អាករពិសេសដើម្បីបញ្ជាក់ថាបានបង់អាករពិសេស។<br>៩- ពាក្យ "អាករ" ក្នុងជំពូកនេះ សំដៅដល់ អាករពិសេស។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | <u>**ជំពូកទី៥ អាករពិសេស**</u><br>**មាត្រា៨៨.- ទំនិញឬសេវាជាប់អាករពិសេស**<br>ដោយមិនកំណត់ត្រឹមតែដូចខាងក្រោមនេះ ទំនិញឬសេវាដែលជាប់អាករពិសេស៖<br>១- ទំនិញមួយចំនួនមានជាអាទិ៍៖<br>ក-ផលិតផលតេលសិលា៖<br>- ប្រេងសាំង<br>- ប្រេងម៉ាស៊ូត<br>- ប្រេងសាំងយន្តហោះ<br>- ប្រេងរំអិល។<br>ខ- ភេសជ្ជៈ៖<br>- ភេសជ្ជៈគ្មានជាតិសុរា មានជាអាទិ៍ ភេសជ្ជៈដែលមានជាតិឧស្ម័ន មានដាក់ស្ករ ឬសារជាតិផ្អែម ឬក្លិនផ្សេងៗ និងភេសជ្ជៈគ្មានជាតិសុរាដទៃទៀតលើកលែងតែទឹកនិងទឹកមីណេរ៉ាល ទឹកដោះគោ និងទឹកដមផ្លែឈើឬបន្លែ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | - ស្រា<br>- ស្រាបៀរ<br>- ភេសជ្ជៈមេរ័យផ្សេងទៀត។<br>គ- បារី បារីស៊ីហ្គា និងបារីគ្រប់ប្រភេទ<br>ឃ- គ្រឿងអេឡិចត្រូនិក<br>ង- ទោចក្រយានយន្ត<br>ច- រថយន្ត<br>ឆ- គ្រឿងបន្លាស់យានយន្ត<br>ជ- ផលិតផលប្លាស្ទិក<br>ឈ- ផលិតផលគ្រឿងសម្អាង<br>ញ- ផលិតផលកញ្ចក់ជាគ្រឿងសំណង់<br>ដ- ស៊ីម៉ង់ត៍។<br>២- សេវាមួយចំនួន មានជាអាទិ៍៖<br>ក- សេវាទូរគមនាគមន៍<br>ខ- សេវាដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាស<br>គ- សេវាលំហែកម្សាន្ត។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យកំណត់បន្ថែម ឬលុបចោលនូវមុខទំនិញឬសេវាជាប់អាករពិសេស តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **មាត្រា៨៩.- អត្រាអាករពិសេស**<br><br>អត្រាអាករពិសេស ត្រូវកំណត់ជាអត្រាភាគរយលើតម្លៃទំនិញ ឬសេវាដែលជាមូលដ្ឋានគិតអាករពិសេស ឬជាតម្លៃកំណត់ទៅលើទម្ងន់ ចំណុះ ទំហំ ឬបរិមាណ។<br><br>អត្រាអាករពិសេសត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br><br>**មាត្រា៩០.- មូលដ្ឋានគិតអាករពិសេស**<br><br>មូលដ្ឋានគិតអាករពិសេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | <u>ជំពូកទី៦ អាករសម្រាប់បំភ្លឺសាធារណៈ</u><br>**មាត្រា៩៥.- អត្រាអាករ**<br>អត្រាអាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>**មាត្រា៩៦.- មូលដ្ឋានគិតអាករ**<br>មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **<u>ជំពូកទី៧ អាករលើការស្នាក់នៅ</u>**<br><br>**មាត្រា១០៥._ ពេលផ្តល់ផ្គង់**<br><br>វិធាននៃការផ្តល់ផ្គង់សេវាស្នាក់នៅ ត្រូវអនុវត្តស្របតាមវិធាននៃការផ្តល់ផ្គង់សេវាសម្រាប់អាករលើតម្លៃបន្ថែមដូចមានចែងក្នុងមាត្រា៦១ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **ជំពូកទី៨ ពន្ធប៉ាតង់**<br>**មាត្រា១១០.. ការលើកលែងពន្ធ**<br>ពន្ធប៉ាតង់ត្រូវបានលើកលែងដូចខាងក្រោម៖<br>១- ស្ថាប័នរដ្ឋ បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការ បច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។<br>២- សកម្មភាពរបស់អង្គការណាមួយដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។<br>៣- គ្រប់សកម្មភាពអាជីវកម្មដែលមានផលរបរប្រចាំឆ្នាំក្រោមកម្រិតផលរបរអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានកំណត់ក្នុងមាត្រា៦ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **មាត្រា១១១_អត្រាពន្ធ**<br>អត្រាពន្ធប៉ាតង់ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ ( ត )

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង ( ត )

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | <u>ជំពូកទី១៥ ពន្ធលើដីធ្លីមិនបានប្រើប្រាស់</u><br>**មាត្រា១៧៨.- ការលើកលែងពន្ធ**<br>ការលើកលែងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>**មាត្រា១៧៩.- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ**<br>កម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃដីធ្លីមិនបានប្រើប្រាស់ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។<br>**មាត្រា១៨៣.- និយមន័យ**<br>សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្ដីពីពន្ធលើមធ្យោបាយដឹកជញ្ជូន ពាក្យ "មធ្យោបាយដឹកជញ្ជូន" សំដៅដល់ មធ្យោបាយដឹកជញ្ជូន ឬយានជំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប័រ រថយន្ត ក្បាលរថយន្តសណ្ដោង រ៉ឺម៉កសណ្ដោង ស៊ីមីរ៉ឺម៉កសណ្ដោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។ |

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | **ជំពូកទី១៦ ពន្ធលើមធ្យោបាយដឹកជញ្ជូន**<br><br>**មាត្រា១៨៤.‒ អត្រាពន្ធ**<br><br>ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវកំណត់ទៅតាមប្រភេទមធ្យោបាយដឹកជញ្ជូនដូចខាងក្រោម៖<br>១- រថយន្តដឹកទំនិញ។<br>២- ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង។<br>៣- រថយន្តដឹកអ្នកដំណើរ។<br>៤- ជលយាន ឬជលយានយន្ត។<br>៥- រថយន្តទេសចរណ៍។<br>៦- យាន ឬយានយន្តកែច្នៃ។<br><br>អត្រាពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **មាត្រា១៨៥_ បន្ទុកនៃពន្ធ**<br>ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវអនុវត្តលើម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន។<br>**មាត្រា១៨៧_ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ**<br>ម្ចាស់កម្មសិទ្ធិមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | <u>**ជំពូកទី១៧ វិធាននិននីតិវិធីសារពើពន្ធ**</u><br><br>**មាត្រា១៩៦_ សិទ្ធិអំណាចក្នុងគ្រាដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**<br><br>១- ក្នុងករណីដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្ន ឬតម្រូវការចាំបាច់បន្ទាន់នានា ក្នុងការធានាលំនឹងជីវភាពនិងសុខុមាលភាពរបស់ប្រជាជន និងធានាប្រក្រតីភាពនៃកិច្ចដំណើរការសេដ្ឋកិច្ច និងសង្គម រាជរដ្ឋាភិបាលអាចសម្រេចផ្តល់ការអនុគ្រោះ ឬលើកលែង ឬព្យួរប្រភេទពន្ធណាមួយភ្លាម មួយផ្នែក ឬទាំងស្រុង តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ២- ការផ្តល់ការអនុគ្រោះ ឬការលើកលែង ឬការព្យួរប្រភេទពន្ធណាមួយ ដូចមានចែងក្នុងកថាខណ្ឌខាងលើ នឹងត្រូវជាកម្មវត្ថុនៃការធ្វើនិយ័តភាវូបនីយកម្មដោយច្បាប់ហិរញ្ញវត្ថុនាពេលបន្ទាប់។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **ជំពូកទី១៧ វិធាននិននីតិវិធីសារពើពន្ធ**<br><br>**មាត្រា២១៥.. ការផ្ទេរអាជីវកម្មឬការផ្ទេរភាគហ៊ុននិងការរួមបញ្ចូលគ្នានៃសហគ្រាស**<br><br>១- ក្នុងករណីមានការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន ម្ចាស់កម្មសិទ្ធិថ្មីត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់របស់អាជីវកម្ម ឬសហគ្រាស។<br><br>២- ក្នុងករណីការរំលាយបញ្ចូលគ្នានៃសហគ្រាស ២ (ពីរ)ឬច្រើន សហគ្រាសដែលនៅបន្តឬកើតពីការរំលាយបញ្ចូលគ្នានៃសហគ្រាស ២(ពីរ)ឬច្រើន ត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២២៧_ មូលហេតុនៃការរំលត់បណ្តឹងអាជ្ញា**<br>១- ការសម្របសម្រួលជាមួយរដ្ឋបាលសារពើពន្ធ តាមរយៈការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់នាំឱ្យបណ្តឹងអាជ្ញារលត់ចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធយល់ព្រមធ្វើការសម្របសម្រួល រដ្ឋបាលសារពើពន្ធត្រូវធ្វើកំណត់ហេតុអំពីការសម្របសម្រួលនេះ ហើយបញ្ជូនទៅស្ថាប័នអយ្យការ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច។<br>២- បទប្បញ្ញត្តិនៃកថាខណ្ឌ១ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | <u>**ជំពូកទី១៨ ទោសប្បញ្ញត្តិ**</u><br><br>**មាត្រា២៣១.- ប្រភេទទោសទណ្ឌរដ្ឋបាល**<br><br>១- ទណ្ឌកម្មរដ្ឋបាលដែលកំណត់ក្នុងច្បាប់នេះ រួមមាន ពន្ធបន្ថែម ការប្រាក់ ការផាកពិន័យជាប្រាក់ ការព្យួរឬការដកហូតអាជ្ញាបណ្ណ ការបិទអាជីវកម្មជាបណ្ដោះអាសន្ន និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br><br>២- ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។ អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ អាចទទួលបានសិទ្ធិក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល តាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការតវ៉ាចំពោះការសម្រេចរបស់អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ ត្រូវអនុវត្តស្របតាមមាត្រា២៣៦ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **<u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u>**<br><br>**មាត្រា២៣៤.- ការព្រមានជាលាយលក្ខណ៍អក្សរ**<br><br>ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយរដ្ឋបាលសារពើពន្ធចំពោះបុគ្គលដែលប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌ១ កថាខណ្ឌ២ និងកថាខណ្ឌ៣ នៃមាត្រា២២៥ នៃច្បាប់នេះ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៤១.- ការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់**<br>១- រដ្ឋបាលសារពើពន្ធ អាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមការកំណត់ក្នុងច្បាប់នេះ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ នៅពេលដែលសេចក្តីសម្រេចនេះចូលជាស្ថាពរ។<br>២- ក្នុងករណីចាំបាច់ និងដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ចូលជាស្ថាពរ បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យជាប្រាក់បានចូលជាស្ថាពរ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២៤៥.- ការប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ**<br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ២០ ០០០ ០០០ (ម្ភៃលាន)រៀល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៤៦_ការខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច**<br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៤៧_ ការប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល**<br>ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលធ្វើការប្រមូលប្រាក់ពន្ធ ដោយមិនទទួលបានសិទ្ធិពីរដ្ឋឬការអនុញ្ញាតស្របតាមការកំណត់របស់ច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២៤៨.- ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់មន្ត្រីពន្ធដារ**<br>មន្ត្រីពន្ធដារទាំងឡាយណាដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ទណ្ឌកម្មរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | ➡ | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៤៩_ ការទទួលខុសត្រូវរបស់នីតិបុគ្គល**<br>១- នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់នេះ។<br>២- ចំពោះនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | ៣- ចំពោះនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៣ មាត្រា២៤៦ និងមាត្រា២៤៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល។<br><br>៤- ចំពោះនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។<br><br>៥- ចំពោះនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៥០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។<br><br>៦- នីតិបុគ្គលអាចត្រូវប្រកាសទោសបន្ថែមណាមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **<u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u>**<br><br>**មាត្រា២៥០.- ការទទួលខុសត្រូវរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិត**<br><br>អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ដែលមានជាអាទិ៍ ជួយជ្រោមជ្រែង អូសទាញ ផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | <u>ជំពូកទី១៨ ទោសប្បញ្ញត្តិ</u><br>**មាត្រា២៥១.- ការប្រព្រឹត្តបទល្មើសពុករលួយ**<br>១- ចំពោះបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា ២៤៣ មាត្រា២៤៦ និងមាត្រា២៤៧នៃច្បាប់នេះ ហើយដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ត្រូវកំណត់ថាជាបទល្មើសពុករលួយ ដែលត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។<br>២- ការស៊ើបអង្កេតបទល្មើសពុករលួយក្នុងវិស័យពន្ធដារ និងការកសាងសំណុំរឿងពុករលួយនៅក្នុងវិស័យនេះទៅតុលាការ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | **ជំពូកទី១៨ ទោសប្បញ្ញត្តិ**<br>**មាត្រា២៥២.- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**<br>ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៨នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីអំពើដែលកំណត់ថាជាបទល្មើសដូចមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## គ- ចំនួនមាត្រាដែលត្រូវបានធ្វើការបន្ថែមថ្មីទាំងស្រុង (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| | → | <u>ជំពូកទី១៩ អន្តរប្បញ្ញត្តិ</u><br>មាត្រា២៥៣.- អន្តរប្បញ្ញត្តិ<br>លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងវិសោធនកម្មជាបន្តបន្ទាប់ ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ២.២. មាត្រាដែលត្រូវបានធ្វើវិសោធនកម្មមានចំនួន ២៤៦មាត្រា

### ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន៖ ៥៨មាត្រា

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី២ ពន្ធលើប្រាក់ចំណូល (២មាត្រា) | មាត្រា៩, មាត្រា១២ |
| ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស (២មាត្រា) | មាត្រា៤០, មាត្រា៤១ |
| ជំពូកទី៦ អាករសម្រាប់បំភ្លឺសាធារណៈ (៥មាត្រា) | មាត្រា៩២, មាត្រា៩៣, មាត្រា៩៤, មាត្រា៩៧, មាត្រា៩៨ |
| ជំពូកទី៧ អាករលើការស្នាក់នៅ (៦មាត្រា) | មាត្រា១០០, មាត្រា១០១, មាត្រា១០២, មាត្រា១០៣, មាត្រា១០៤, មាត្រា១០៦ |
| ជំពូកទី៨ ពន្ធប៉ាតង់(៥មាត្រា) | មាត្រា១០៨, មាត្រា១០៩, មាត្រា១១២, មាត្រា១១៣, មាត្រា១១៤ |
| ជំពូកទី៩ ពន្ធលើផ្ទាំងផ្សព្វផ្សាយ (៥មាត្រា) | មាត្រា១១៨, មាត្រា១១៩, មាត្រា១២០, មាត្រា១២១, មាត្រា១២២ |
| ជំពូកទី១១ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ (៧មាត្រា) | មាត្រា១៣៩, មាត្រា១៤០, មាត្រា១៤១, មាត្រា១៤២, មាត្រា១៤៣, មាត្រា១៤៤, មាត្រា១៤៥ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ជំពូក | មាត្រា |
|---|---|
| ជំពូកទី១២ ពន្ធលើអចលនទ្រព្យ(៦មាត្រា) | មាត្រា១៤៨, មាត្រា១៤៩, មាត្រា១៥០, មាត្រា១៥១, មាត្រា១៥២, មាត្រា១៥៣ |
| ជំពូកទី១៣ ពន្ធប្រថាប់ត្រា(៨មាត្រា) | មាត្រា១៥៦, មាត្រា១៥៧, មាត្រា១៥៨, មាត្រា១៥៩, មាត្រា១៦០, មាត្រា១៦១, មាត្រា១៦២, មាត្រា១៦៣ |
| ជំពូកទី១៤ ពន្ធលើចំណេញមូលធន(៦មាត្រា) | មាត្រា១៦៦, មាត្រា១៦៧, មាត្រា១៦៨, មាត្រា១៦៩, មាត្រា១៧០, មាត្រា១៧១ |
| ជំពូកទី១៥ ពន្ធលើដីធ្លីមិនបានប្រើប្រាស់(៤មាត្រា) | មាត្រា១៧៣, មាត្រា១៧៥, មាត្រា១៧៦, មាត្រា១៧៧ |
| ជំពូកទី១៦ ពន្ធលើមធ្យោបាយដឹកជញ្ជូន(១មាត្រា) | មាត្រា១៨៦ |
| ជំពូកទី១៨ ទោសប្បញ្ញត្តិ(១មាត្រា) | មាត្រា២២៩ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)
*ដកស្រង់ទាំង១៣ជំពូក

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៩ .-ថ្មី ប្រាក់ចំណូលលើកលែងពន្ធ**<br><br>ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចតទៅ៖<br>១-វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ពន្ធលើប្រាក់ចំណូល មិនត្រូវអនុវត្តចំពោះ៖<br>ក-ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល<br>ខ- ប្រាក់ចំណូលរបស់អង្គការណាមួយដែល៖<br>- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ<br>- គ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន | → | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា៩.- ប្រាក់ចំណូលលើកលែងពន្ធ**<br><br>ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចខាងក្រោម៖<br>១- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ពន្ធលើប្រាក់ចំណូល មិនត្រូវអនុវត្តចំពោះ៖<br>ក- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល<br>ខ- ប្រាក់ចំណូលរបស់៖<br>- អង្គការណាមួយដែលត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធ ខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូល ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | ច្បាប់ថ្មី |
| --- | --- |
| គ- ប្រាក់ចំណូលរបស់អង្គការពលករឬសភាពាណិជ្ជកម្ម ឧស្សាហកម្មឬកសិកម្ម ក្នុងករណីដែលប្រាក់ចំណូលរបស់អង្គការទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល<br>ឃ- ប្រាក់ចំណូលដែលបានមកពីការលក់ផលិតផលកសិកម្ម ដែលបុគ្គលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសផលិតបានដោយខ្លួនឯង ទោះបីផលិតផលនោះមិនទាន់កែច្នៃឬកែច្នៃហើយក៏ដោយទៅតាមទម្លាប់នៃការងារកសិកម្ម។ ប្រតិបត្តិការតាមមធ្យោបាយឧស្សាហកម្មរួមទាំងការកែច្នៃ ការរក្សាគុណភាព ការវេចខ្ចប់សម្រាប់លក់ពុំត្រូវបានចាត់ទុកជាទម្លាប់នៃការងារកសិកម្មឡើយ។ | - សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគមនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល។<br>គ- ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា២០ មាត្រា២៣ និងមាត្រា២៦ នៃច្បាប់នេះ ត្រូវបានបង់រួចរាល់។<br>២- ក្នុងករណីប្រាក់ចំណូលដូចមានចែងក្នុងវាក្យខណ្ឌខ នៃកថាខណ្ឌទី១ នៃមាត្រានេះត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល ប្រាក់ចំណូលទាំងនោះត្រូវបានកំណត់ឱ្យជាប់ពន្ធឡើងវិញ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ២- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសអំពីនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ការប្រកាសសារពើពន្ធ និងការចុះបញ្ជី។ | → | ៣- ក្នុងករណីអង្គការឬសមាគមដូចមានចែងក្នុងវាក្យខណ្ឌខ នៃកថាខណ្ឌទី១ នៃមាត្រានេះ មានសកម្មភាពខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀត ដែលមិនទាក់ទិនដល់គោលដៅឬមុខងារជាមូលដ្ឋាន នៃការលើកលែងពន្ធរបស់ខ្លួន ប្រាក់ចំណូលដែលបានមកពីសកម្មភាពមិនទាក់ទិនទាំងនោះត្រូវជាប់ពន្ធតាមមាត្រា ២០ នៃច្បាប់នេះ។<br>៤- វិធាននិងនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី១ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា១២ .- ចំណាយការប្រាក់**<br>ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធ និង ៥០ភាគរយ នៃប្រាក់ចំណូលសុទ្ធ ក្រៅពីការប្រាក់របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ។<br>ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ ដកខ្ទង់ចំណាយនានាដែលអនុញ្ញាតឱ្យផាត់ចេញលើកលែងតែចំណាយការប្រាក់។<br>ចំណាយការប្រាក់ដែលសល់ពីការកាត់កងខាងលើត្រូវចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយការផាត់ចេញត្រូវអនុវត្តតាមខ្លឹមសារនៃមាត្រានេះដូចគ្នា។ | | **ជំពូកទី២ ពន្ធលើប្រាក់ចំណូល**<br><br>**មាត្រា១២.- ចំណាយការប្រាក់**<br>១- ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធនិង៥០(ហាសិប)ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ។<br>២- ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ដកខ្ទង់ចំណាយនានាដែលអនុញ្ញាតឱ្យកាត់កង លើកលែងតែចំណាយការប្រាក់។<br>៣- វិធាននិងនីតិវិធីនៃការយោងទៅមុខនៃចំណាយការប្រាក់ ដែលសល់ពីការកាត់កងខាងលើត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| **ជំពូកទី២ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស**<br><br>**មាត្រា៤១ .- កម្មវត្ថុនៃពន្ធ**<br>ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។<br>រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស។<br>រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។ | | **ជំពូកទី៣ ពន្ធលើប្រាក់បៀវត្ស**<br><br>**មាត្រា៤០.- កម្មវត្ថុនៃពន្ធ**<br>ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។<br><br>**មាត្រា៤១.- វិសាលភាពនៃពន្ធ**<br>១- រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា និងប្រាក់បៀវត្សប្រភពបរទេស។<br>២- រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខនស/រកម/០១៩៩/០១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៨* | → | **ជំពូកទី៦ អាករសម្រាប់បំភ្លឺសាធារណៈ**<br>មាត្រា៩២.. កម្មវត្ថុនៃអាករ<br>មាត្រា៩៣.. វិសាលភាពនៃអាករ<br>មាត្រា៩៤.. និយមន័យ<br>មាត្រា៩៥.. អត្រាអាករ<br>មាត្រា៩៦.. មូលដ្ឋានគិតអាករ<br>មាត្រា៩៧.. ពេលផ្តត់ផ្តង់<br>មាត្រា៩៨.. កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា៩៩.. វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ |


ច្បាប់
ស្តីពី
ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
ជំពូកទី១

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខនស/រកម/១២០៤/០០២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៤* | → | **ជំពូកទី៧ អាករលើការស្នាក់នៅ**<br>មាត្រា១០០.- កម្មវត្ថុនៃអាករ<br>មាត្រា១០១.- វិសាលភាពនៃអាករ<br>មាត្រា១០២.- និយមន័យ<br>មាត្រា១០៣.- អត្រាអាករ<br>មាត្រា១០៤.- មូលដ្ឋានគិតអាករ<br>មាត្រា១០៥.- ពេលផ្ដត់ផ្គង់<br>មាត្រា១០៦.- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១០៧.- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ |



ព្រះរាជក្រម

នស/រកម/១២០៤/០០២

យើង

មាត្រា ៨.-

ត្រូវបានបង្កើតអាករលើការស្នាក់នៅសំរាប់ជាគុណប្រយោជន៍ដល់ថវិកាខេត្ត ក្រុង ។

អាករលើការស្នាក់នៅត្រូវកំណត់តាមអត្រា២ភាគរយ លើថ្លៃស្នាក់នៅក្នុងសណ្ឋាគារ ។

ប្រាក់អាករលើការស្នាក់នៅត្រូវកំណត់ និងត្រូវបង់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្ដត់ផ្គង់ ។ វិធាននៃការផ្ដត់ផ្គង់សេវាស្នាក់នៅ ត្រូវបានអនុវត្តដូចគ្នាទៅនឹងវិធាននៃការផ្គត់ផ្គង់សេវាសំរាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងមាត្រា ៦២ នៃច្បាប់ស្ដីពីសារពើពន្ធ ។

បែបបទនៃការអនុវត្តអាករស្នាក់នៅនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
| --- | --- | --- |
| *ក្រឹត្យ-ច្បាប់លេខ២២ ក្រ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥* | → | **ជំពូកទី៨ ពន្ធប៉ាតង់**<br>មាត្រា១០៨.. កម្មវត្ថុនៃពន្ធ<br>មាត្រា១០៩.. វិសាលភាពនៃពន្ធ<br>មាត្រា១១០.. ការលើកលែងពន្ធ<br>មាត្រា១១១.. អត្រាពន្ធ<br>មាត្រា១១២.. កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១១៣.. សកម្មភាពនិងទីកន្លែងប្រកបអាជីវកម្មជាប់ពន្ធ<br>មាត្រា១១៤.. បណ្ណពន្ធប៉ាតង់<br>មាត្រា១១៥.. វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |

រាជាណាចក្រកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ
លេខ : ២២ ក្រ.ច

ក្រឹត្យ-ច្បាប់
ស្តីពី
ពន្ធប៉ាតង់

V-ពន្ធប៉ាតង់

មាត្រា ៣៩-
ចំនួនប្រាក់ពន្ធប៉ាតង់ដែលបានកំណត់ទុកក្នុងក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៨៥ ត្រូវបានកែប្រែនិងជំនួសដោយចំនួនប្រាក់ពន្ធដូចមានចែងក្នុងតារាងខាងក្រោម ៖

| ថ្នាក់ប៉ាតង់ | ផលរបរប្រចាំឆ្នាំ | | ចំនួនប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំ |
| --- | --- | --- | --- |
| | សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម | សកម្មភាពសេវាកម្មលើកលែងតែ ថ្លៃកម្រៃបញ្ចុក និងធនាគារ | |
| ១ | ដល់ ៧.៤០០.០០០៛ | ដល់ ៣.០០០.០០០៛ | ១៥.០០០ |
| ២ | ពី ៧.៤០០.០០១- ១២.៤០០.០០០៛ | ពី ៣.០០០.០០១- ៥.០០០.០០០៛ | ២១.០០០ |
| ៣ | - ១២.៤០០.០០១- ២៥.០០០.០០០៛ | - ៥.០០០.០០១- ១០.០០០.០០០៛ | ២៧.០០០ |
| ៤ | - ២៥.០០០.០០១- ៣០.០០០.០០០៛ | - ១០.០០០.០០១- ១២.០០០.០០០៛ | ៤០.០០០ |

# ២- ច្បាប់ស្តីពីសារពើពន្ធ ( ឥ )

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន ( ត )

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ន.ស. ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤*  | → | **ជំពូកទី៩ ពន្ធលើផ្ទាំងផ្សព្វផ្សាយ**<br>មាត្រា១១៦.- កម្មវត្ថុនៃពន្ធ<br>មាត្រា១១៧.- វិសាលភាពនៃពន្ធ<br>មាត្រា១១៨.- និយមន័យ<br>មាត្រា១១៩.- ការលើកលែងពន្ធ<br>មាត្រា១២០.- អត្រាពន្ធនិងមូលដ្ឋានគិតពន្ធ<br>មាត្រា១២១.- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១២២.- ការខកខានមិនបានដាក់លិខិតប្រកាសនិង បង់ប្រាក់ពន្ធ<br>មាត្រា១២៣.- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២ ន.ស. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣* | → | ជំពូកទី១១ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ<br>មាត្រា១៣៩.._ កម្មវត្ថុនៃពន្ធ<br>មាត្រា១៤០.._ វិសាលភាពនៃពន្ធ<br>មាត្រា១៤១.._ និយមន័យ<br>មាត្រា១៤២.._ អត្រាពន្ធ<br>មាត្រា១៤៣.._ ការលើកលែងពន្ធ<br>មាត្រា១៤៤.._ កាតព្វកិច្ចរបស់កម្មសិទ្ធិករឬសិទ្ធិវន្ត<br>មាត្រា១៤៥.._ កាតព្វកិច្ចរបស់អ្នកជួល<br>មាត្រា១៤៦.._ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |


ច្បាប់

ស្ដីពី

ហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤

ដែលប្រកាសអោយប្រើដោយព្រះរាជក្រម

០២ នស

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣

ពន្ធលើឈ្នួលផ្ទះ និង ដី

ផ្នែកទី I

បទបញ្ញត្តិទូទៅ

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩* | → | **ជំពូកទី១២ ពន្ធអចលនទ្រព្យ**<br>មាត្រា១៤៧._ កម្មវត្ថុនៃពន្ធ<br>មាត្រា១៤៨._ វិសាលភាពនៃពន្ធ<br>មាត្រា១៤៩._ និយមន័យ<br>មាត្រា១៥០._ អត្រាពន្ធ<br>មាត្រា១៥១._មូលដ្ឋានគិតពន្ធ<br>មាត្រា១៥២._ការលើកលែងពន្ធ<br>មាត្រា១៥៣._ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១៥៤._ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |


ព្រះរាជក្រម

នស/រកម/១២០៩/០២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុចិតជាតិសាសនា ក្សត្រខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ផ្នែកទី ២

ពន្ធលើអចលនទ្រព្យ

មាត្រា១៣._

...ងតាមមាត្រា ៧៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលត្រូវបាន
...ប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា
...០១ ... ក្នុងគោលបំណងវិចារណការូបនីយកម្មក្នុងការប្រើប្រាស់ដី និង ...

- 3 -

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើក្រឹត្យលេខ ២១ ក្រ ចុះ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១។*  | | **ជំពូកទី១៣ ពន្ធប្រថាប់ត្រា**<br>មាត្រា១៥៥.- កម្មវត្ថុនៃពន្ធ<br>មាត្រា១៥៦.- វិសាលភាពនៃពន្ធ<br>មាត្រា១៥៧.- និយមន័យ<br>មាត្រា១៥៨.- អត្រាពន្ធ<br>មាត្រា១៥៩.- មូលដ្ឋានគិតពន្ធ<br>មាត្រា១៦០.- អ្នកជាប់ពន្ធ<br>មាត្រា១៦១.- ការលើកលែងនិងការអនុគ្រោះពន្ធ<br>មាត្រា១៦២.- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១៦៣.- ការខកខានមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១៦៤.- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០០៦។* | → | **ជំពូកទី១៤ ពន្ធលើចំណេញមូលធន**<br>មាត្រា១៦៥.- កម្មវត្ថុនៃពន្ធ<br>មាត្រា១៦៦.- វិសាលភាពនៃពន្ធ<br>មាត្រា១៦៧.- និយមន័យ<br>មាត្រា១៦៨.- អត្រាពន្ធ<br>មាត្រា១៦៩.- ការលើកលែងពន្ធ<br>មាត្រា១៧០.- វិធាននៃការកាត់កងចំណាយ<br>មាត្រា១៧១.- កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១៧២.- វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |



មាត្រា ១៦.–
បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧.–
ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

មាត្រា ៤.–ថ្មី
មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៧.–ថ្មី
ប្រាក់ចំណេញជាប់ពន្ធ គឺជាប្រាក់ចំណេញសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬ នៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល និង សួយសារ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬ ទ្រព្យសកម្មវិនិយោគ រាប់ទាំងអចលនទ្រព្យផង ។ ប្រាក់ចំណេញជាប់ពន្ធក៏រួមបញ្ចូលផងដែរនូវចំណេញមូលធនទាំងអស់ពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬ ទ្រព្យវិនិយោគ ដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលសម្រេចបានមកពីប្រតិបត្តិការនានាក្រៅពីប្រតិបត្តិការអាជីវកម្ម ។ និយមន័យនៃពាក្យ"អចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ទ្រព្យវិនិយោគ ការសម្រេចបាន" ព្រមទាំងការកំណត់មូលដ្ឋានគិតពន្ធ វិធាន និងនីតិវិធីនៃការប្រមូល ប្រាក់ពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤។* | → | **ជំពូកទី១៥ ពន្ធលើដីធ្លីមិនបានប្រើប្រាស់**<br>មាត្រា១៧៣._ កម្មវត្ថុនៃពន្ធ<br>មាត្រា១៧៥._ និយមន័យ<br>មាត្រា១៧៦._ អត្រាពន្ធ<br>មាត្រា១៧៧._ មូលដ្ឋានគិតពន្ធ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១១ ន.ស ៩៤

III- ពន្ធលើដីធ្លីមិនបានប្រើប្រាស់

មាត្រា ២៦.-

ត្រូវបានបង្កើតពន្ធដីធ្លីលើដីមិនបានប្រើប្រាស់ ដើម្បីជាប្រយោជន៍ថវិកាជាតិ ។

មាត្រា ២៧.-

ពន្ធនេះកំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់ពោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

មាត្រា ២៨.-

ត្រូវបានបង្កើតគណៈកម្មការមួយហៅថា គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ដែលមានសមាសភាពកំណត់ដោយអនុក្រឹត្យ ។

គណៈកម្មការនេះមានភារកិច្ច ៖

- បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុង ១ ម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ

# ២- ច្បាប់ស្តីពីសារពើពន្ធ (ត)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| *ច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើក្រឹត្យលេខ ២៤ ក្រ ចុះថ្ងៃទី ២០ ខមិថុនា ឆ្នាំ១៩៩១។*  | | ជំពូកទី១៦ ពន្ធលើមធ្យោបាយដឹកជញ្ជូន<br>មាត្រា១៨១._ កម្មវត្ថុនៃពន្ធ<br>មាត្រា១៨២._ វិសាលភាពនៃពន្ធ<br>មាត្រា១៨៣._ និយមន័យ<br>មាត្រា១៨៤._ អត្រាពន្ធ<br>មាត្រា១៨៥._ អ្នកជាប់ពន្ធ<br>មាត្រា១៨៦._ ការលើកលែងពន្ធ<br>មាត្រា១៨៧._ កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ<br>មាត្រា១៨៨._ វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ |

# ២- ច្បាប់ស្ដីពីសារពើពន្ធ (ឥ)

## ឃ- ចំនួនមាត្រាដែលត្រូវបានដកស្រង់ចេញពីបទប្បញ្ញត្តិជាធរមាន (ត)

| ច្បាប់ចាស់ | | ច្បាប់ថ្មី |
|---|---|---|
| ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤<br><br>**មាត្រា ១៣.-**<br>មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឲ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។<br>របៀបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។<br>៨/១១<br>រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារក្នុងការពិនិត្យ និងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ច ដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ។ | → | <u>**ជំពូកទី១៨ ទោសប្បញ្ញត្តិ**</u><br>***មាត្រា២២៩.- នីតិសម្បទាជានគរបាលយុត្តិធម៌របស់មន្ត្រីពន្ធដារ***<br>១- មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។<br>២- បែបបទនិងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។<br>៣- រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារ ដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋបាលសារពើពន្ធមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ចដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ។ |

# សូមអរគុណ

# Thank you